# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
និង
របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា
សម្រាប់សហគ្រាសធុនតូច និង មធ្យម

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

# ខេមរា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## មាតិកា

*ទំព័រ*


របាយការណ៍របស់ក្រុមប្រឹក្សាភិបាល....................................................................................................1 - 5
របាយការណ៍របស់សវនករឯករាជ្យ ....................................................................................................6 - 9
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ....................................................................................................10
របាយការណ៍លទ្ធផលពេញលេញ....................................................................................................11
របាយការណ៍បម្រែបម្រួលមូលធន....................................................................................................12
របាយការណ៍លំហូរសាច់ប្រាក់ ....................................................................................................13
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ....................................................................................14 - 43

ខេមា មីក្រូហិរញ្ញវត្ថុ
CAMMA MICROFINANCE

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន") ធ្វើការបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

### ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាប័ណ្ណ និងបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត តាមបញ្ជីការលេខ Co. 0700 KH/2010 ចុះថ្ងៃទី6 ខែមេសា ឆ្នាំ2010។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ក្នុងការធ្វើប្រតិបត្តិការសេវាកម្មមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី29 ខែកក្កដា ឆ្នាំ2010។

ទស្សនៈវិស័យរបស់ក្រុមហ៊ុន គឺដើម្បីក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏មានទំនុកចិត្តមួយ ក្នុងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុច្រើនយ៉ាង ជាមួយនិងភាពច្នៃប្រឌិតដល់ប្រជាជនកម្ពុជា និងរក្សាបាននូវអត្ថប្រយោជន៍ជូនអតិថិជន និយោជិក ភាគទុនិក និងសង្គមជាតិទាំងមូល។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងមានឥទ្ធិពលដល់សហគមន៍សហគ្រាសធុនតូច និងមធ្យម និងកសិករ ជាពិសេស ប្រកបដោយប្រសិទ្ធភាព និរន្តភាព និង ភាពទំនួលខុសត្រូវខ្ពស់។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន ស្ថិតនៅផ្ទះលេខ101A ផ្លូវលេខ289 សង្កាត់បឹងកក់ទី1 ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### ដើមទុន

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ដើមទុនទូទាត់មានចំនួន 5,593,000 ដុល្លារអាមេរិក ឬ 22,372,000 ពាន់រៀល (ឆ្នាំ2020៖ មានចំនួន 3,593,000 ដុល្លារអាមេរិក ឬ 14,372,000 ពាន់រៀល)

### ភាគលាភ

ក្រុមហ៊ុនមិនមានការប្រកាស ឬទូទាត់ភាគលាភនោះទេ។ ក្រុមប្រឹក្សាភិបាល មិនបានផ្តល់អនុសាសន៍ក្នុងការទូទាត់ភាគលាភ នៅក្នុងឆ្នាំនោះទេ។

### ទុនបម្រុង និងសំវិធានធន

ពុំមានបម្រែបម្រួលជាសារវន្តលើទុនបម្រុង និង សំវិធានធនសម្រាប់ការិយបរិច្ឆេទនេះទេ លើកលែងតែបម្រែបម្រួលដែលត្រូវបានលាតត្រដាងបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។



គ្រឹះស្ថានឯកជន
Private Company
ផ្ទះលេខ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ភ្នំពេញ
ADDRESS # 101A, ST.289, BOEUNG KAK 1, TOUL KORK, PHNOM PENH
TEL: (855) 23 533 9999 , 089 666 014 WEBSITE: WWW.CAMMA.COM.KH

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យនៅអតិថិជន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយជឿជាក់ថា រាល់ឥណទានអាក្រក់ដែលបានដឹង ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបានប៉ាន់ស្មានគ្រប់គ្រាន់សម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់ នៃឥណទានអាក្រក់ដែលបានលុបចោល ឬ ចំនួនទឹកប្រាក់សំវិធានធនលើបំណុលអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

### ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយទ្រព្យសកម្មចរន្ត លើកលែងតែពាក់ព័ន្ធជាមួយឥណទាន ដែលសន្និដ្ឋានថាមិនអាចទទួលស្គាល់ក្នុងតំលៃដើម ដូចដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុននោះ ត្រូវបានកាត់បន្ថយឲ្យស្មើនឹងតម្លៃដែលរំពឹងទុកថានឹងទទួលបាន។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយ ដែលអាចបណ្តាលឲ្យការកំណត់តម្លៃនៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានការយល់ច្រឡំជាសារវន្តនោះទេ។

### វិធីសាស្រ្តកំណត់តម្លៃ

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង និងធ្វើឲ្យប៉ះពាល់ដល់វិធីសាស្រ្តវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនាំឲ្យមានការយល់ច្រឡំ ឬ មានភាពមិនសមស្របជាសារវន្ត នោះទេ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

- ការដាក់បន្ទុកណាមួយដែលកើតចេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន ក្នុងការធានាបំណុលរបស់បុគ្គលណាមួយចាប់តាំងពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះទេ និង
- បំណុលយថាហេតុទាក់ទងដល់ក្រុមហ៊ុន ដែលបានកើតឡើងចាប់ពីចុងនៃការិយបរិច្ឆេទ នៃរបាយការណ៍នេះ ក្រៅពីបំណុលដែលមានទំនាក់ទំនងជាមួយសកម្មភាពអាជីវកម្មធម្មតារបស់ក្រុមហ៊ុននោះទេ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (តពីទំព័រមុន)

### បំណុលយថាហេតុ និងបំណុលផ្សេងៗ (តពីទំព័រមុន)

ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល គ្មានបំណុលយថាហេតុ ឬ បំណុលផ្សេងៗ របស់ក្រុមហ៊ុនត្រូវបានទាមទាឲ្យសង ឬ អាចនឹងទាមទារឲ្យសងក្នុងអំឡុងពេល 12ខែ បន្ទាប់ពីចុងនៃការិយបរិច្ឆេទនៃរបាយការណ៍នេះ នឹងមាន ឬ អាចនឹងមានផលប៉ះពាល់ជាសារវន្ត លើសមត្ថភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅពេលបំណុលទាំងនោះដល់ពេលដែលត្រូវទូទាត់។

### ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សំខាន់ណាមួយ បានកើតឡើងក្រោយការិយបរិច្ឆេទ រាយការណ៍ដែលតម្រូវឲ្យមានការលាតត្រដាងព័ត៌មាន ឬ ធ្វើនិយ័តកម្ម លើកលែងតែព្រឹត្តិការណ៍ដូចដែលបានលាតត្រដាងបង្ហាញនៅក្នុងកំណត់សម្គាល់ ដែលមានភ្ជាប់ទៅនឹងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

### ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| លោក ធន់ វឌ្ឍនា | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក ខូវ សូវៀត | អភិបាល |
| លោកស្រី ខាត់ សុខគាន | អនុប្រធានក្រុមប្រឹក្សាភិបាល (លាលែងនាថ្ងៃ1 ខែឧសភា ឆ្នាំ2021) |
| លោកស្រី យូ បូរី | អភិបាលឯករាជ្យ (តែងតាំងនាថ្ងៃ1 ខែឧសភា ឆ្នាំ2021) |

### សវនករ

ក្រុមហ៊ុនសវនករឯករាជ្យ Ernst & Young (Cambodia) Ltd គឺជាសវនកររបស់ក្រុមហ៊ុន។

### ភាគហ៊ុនកាន់កាប់ដោយក្រុមប្រឹក្សាភិបាល

មិនមានសមាសភាពនៃក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនទេ។

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនៅចុងការិយបរិច្ឆេទនេះ ពុំមានកិច្ចព្រមព្រៀងណាមួយ (ក្នុងនោះក្រុមហ៊ុនជាភាគីម្ខាង) ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចបង្កលទ្ធភាពដល់សមាជិកនៃក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យ ទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជា ការទិញភាគហ៊ុន ឬ ប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬ របស់សាជីវកម្មដទៃ។

ពុំមានអភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬ មានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈហេតុផលនៃកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬ ជាមួយនឹងក្រុមហ៊ុនដែលអភិបាលនោះជាសមាជិកក្រុមប្រឹក្សាភិបាល ឬ ក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានផលប្រយោជន៍ហិរញ្ញវត្ថុជាសារវន្ត លើកលែងតែអត្ថប្រយោជន៍ទាំងឡាយណា ដែលត្រូវបានលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍ស្តីពី ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និង ត្រឹមត្រូវ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងលទ្ធផលនៃប្រតិបត្តិការ ហើយ និង លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលធ្វើឡើងដោយគណៈគ្រប់គ្រងដែលតម្រូវឲ្យ៖

- អនុម័តគោលនយោបាយគណនេយ្យសមស្របដោយមានការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្នហើយត្រូវអនុវត្តគោលនយោបាយទាំងនោះជាអចិន្ត្រៃយ៍។
- អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និង មធ្យម ("CIFRS for SMEs") ប្រសិនបើមានគម្លាតនៃការអនុវត្ត ដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គម្លាតទាំងនោះគួរតែត្រូវបានលាតត្រដាងព័ត៌មានពន្យល់ និងកំណត់ចំនួនទឹកប្រាក់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុឲ្យបានសមរម្យ។
- រក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងធានាថាប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាព លើកលែងតែក្នុងករណីដែលក្រុមហ៊ុនមិនអាចបន្តសកម្មភាពអាជីវកម្មនាពេលអនាគត និង
- បង្កើតគោលនយោបាយទូទៅសម្រាប់ក្រុមហ៊ុនអនុម័តរាល់ការសម្រេចចិត្ត និងសកម្មភាពទាំងឡាយរបស់ ក្រុមប្រឹក្សាភិបាលដែលមានឥទ្ធិពលលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយនិងធានាថាគោលនយោបាយ និងការសំរេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងសមស្របក្នុង របាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យដែលត្រឹមត្រូវ ត្រូវបានរក្សាទុក និង លាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឲ្យបានត្រឹមត្រូវ សមហេតុផលគ្រប់ពេល ហើយ និង ធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានអនុវត្ត។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុន ហើយម្យ៉ាងទៀតក៏ត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់ និង ស្វែងរកកំហុសចេតនា និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** (តពីទំព័រមុន)

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ ជាក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដូចដែលមានភ្ជាប់ជាមួយនេះ ជាបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមតាម CIFRS for SMEs។

តំណាងឲ្យក្រុមប្រឹក្សាភិបាល

ធន់ វឌ្ឍនា
ប្រធានក្រុមប្រឹក្សាភិបាល

ឌិត នីតា
អគ្គនាយិកាប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី22 ខែមេសា ឆ្នាំ2022

Building a better working world

Ernst & Young (Cambodia) Ltd.
5th Floor, Emerald Building
#64 Preah Norodom Boulevard
Corner Street 178, Sangkat Chey Chumneah
Khan Daun Penh, Phnom Penh, Kingdom of Cambodia

Tel: +855 23 860 450/451
Fax: +855 23 217 805
ey.com

យោង៖ 61522920/22759598

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ៖ ភាគទុនិក នៃ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### *មតិយោបល់*

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន") ដែលមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងរបាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនិងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេប នៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

### *មូលដ្ឋាននៃមតិយោបល់*

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយយោងតាមក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃកម្ពុជា រួមជាមួយនឹងតម្រូវការផ្នែកសីលធម៌ដែលទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំក៏បានបំពេញនូវទំនួលខុសត្រូវផ្នែកសីលធម៌ផ្សេងទៀតរបស់យើងខ្ញុំ ដោយស្របទៅតាមតម្រូវការទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### *ព័ត៌មានផ្សេងៗ*

ព័ត៌មានផ្សេងៗ ដែលបានទទួលនាកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដូចដែលបានបង្ហាញក្នុងទំព័រទី1 ដល់ទី5។ គណៈគ្រប់គ្រងមានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗនេះ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និដ្ឋានជានាអះអាងក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។



A member firm of Ernst & Young Global Limited

EY
Building a better working world

***ព័ត៌មានផ្សេងៗ*** (តពីទំព័រមុន)

ទាក់ទិននឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំ គឺការអានព័ត៌មានផ្សេងៗនេះ ហើយធ្វើការពិចារណា ថាតើព័ត៌មានផ្សេងៗនេះ មានភាពខុសគ្នាជាសារវន្ត ឬទេ ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬ ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការធ្វើសវនកម្ម ឬថាតើព័ត៌មានផ្សេងៗនេះ មានកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្ត លើព័ត៌មានផ្សេងៗនេះ ដោយផ្អែកលើការងារដែលបានអនុវត្ត យើងខ្ញុំតម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានហេតុការណ៍អ្វីដែលតម្រូវឲ្យរាយការណ៍ចំពោះព័ត៌មានផ្សេងៗនេះទេ។

## ***ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ***

គណៈគ្រប់គ្រងក្រុមហ៊ុន ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាម CIFRS for SMEs ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលទ្ធភាពនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង (ប្រសិនបើមាន) នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងនិរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬ បញ្ឈប់ប្រតិបត្តិការក្រុមហ៊ុន ឬ គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

អ្នកទទួលបន្ទុកលើអភិបាលកិច្ច មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការនៃការរាយការណ៍អំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ***ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ***

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្មដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ (តែមួយ ឬ បញ្ចូលគ្នាជារួម) ដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖



A member firm of Ernst & Young Global Limited

Building a better working world

***ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

- កំណត់ និងវាយតម្លៃហានិភ័យលើកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ បង្កើត និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំមានកម្រិតខ្ពស់ជាង កំហុសឆ្គងដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬ មិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀត ដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋានទៅលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងនៅក្នុងប្រព័ន្ធគណនេយ្យ និងតាមរយៈភស្តុតាងសវនកម្ម ដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋានលើវត្តមាន នៃភាពមិនប្រាកដប្រជា ជាសារវន្ត ទាក់ទងនឹងព្រឹត្តិការណ៍ ឬ កាលៈទេសៈទាំងឡាយណា ដែលនាំឲ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានវត្តមាន នៃភាពមិនប្រាកដប្រជា ជាសារវន្ត យើងខ្ញុំ តម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករលើកំណត់សម្គាល់ពាក់ព័ន្ធដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំ នឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬ កាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យក្រុមហ៊ុនមិនអាចបន្តនិរន្តរភាពអាជីវកម្មបានផងដែរ។
- វាយតម្លៃការដាក់បង្ហាញទម្រង់ និងមាតិកាទាំងស្រុងនៃរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថារបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការ និងព្រឹត្តិការណ៍ ដែលជាមូលដ្ឋានដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវ។

Building a better
working world

***ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាព ដែលបានគ្រោងទុក និងពេលវេលានៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងពេលធ្វើសវនកម្ម។

ឡុន ស៊ីនរតនា
ដៃគូសវនករ

**អ៊ីនស្ទ័ អេន យ៉ាំង (ខេមបូឌា)**
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី22 ខែមេសា ឆ្នាំ2022



A member firm of Ernst & Young Global Limited

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021

| | *កំណត់សម្គាល់* | *2021* | | *2020* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 4 | 192,475 | 784,143 | 270,273 | 1,093,254 |
| សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា | 5 | 328,394 | 1,337,877 | 182,298 | 737,395 |
| សមតុល្យនៅធនាគារផ្សេងៗ | 6 | 630,550 | 2,568,861 | 80,837 | 326,986 |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 7 | 15,203,043 | 61,937,197 | 13,118,824 | 53,065,643 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 96,018 | 391,178 | 76,656 | 310,076 |
| ទ្រព្យ និងហត្ថូបករណ៍ | 9 | 75,845 | 308,993 | 64,226 | 259,794 |
| កម្មវិធីកុំព្យូទ័រ | 10 | - | - | 6,784 | 27,441 |
| ពន្ធពន្យាជាទ្រព្យសកម្ម | 11.3 | - | - | 5,684 | 22,992 |
| **ទ្រព្យសកម្មសរុប** | | **16,526,325** | **67,328,249** | **13,805,582** | **55,843,581** |
| **ទ្រព្យអកម្ម និងមូលធនម្ចាស់ភាគហ៊ុន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| បំណុលពន្ធលើប្រាក់ចំណូល | 11.2 | 10,108 | 41,180 | 28,765 | 116,354 |
| ប្រាក់កម្ចី | 12 | 9,477,204 | 38,610,129 | 9,036,231 | 36,551,554 |
| ទ្រព្យអកម្មផ្សេងៗ | 13 | 70,632 | 287,755 | 76,861 | 310,903 |
| ពន្ធពន្យារជាទ្រព្យអកម្ម | 11.3 | 39,590 | 161,290 | - | - |
| **ទ្រព្យអកម្មសរុប** | | **9,597,534** | **39,100,354** | **9,141,857** | **36,978,811** |
| **មូលធនម្ចាស់ភាគហ៊ុន** | | | | | |
| ដើមទុន | 14 | 5,593,000 | 22,372,000 | 3,593,000 | 14,372,000 |
| ប្រាក់ចំណេញរក្សាទុក | | 754,748 | 3,080,271 | 713,131 | 2,912,314 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 15 | 581,043 | 2,362,916 | 357,594 | 1,452,585 |
| លម្អៀងបង្គរពីការប្រែសម្រួលរូបិយប័ណ្ណ | | - | 412,708 | - | 127,871 |
| **មូលធនម្ចាស់ភាគហ៊ុនសរុប** | | **6,928,791** | **28,227,895** | **4,663,725** | **18,864,770** |
| **ទ្រព្យអកម្ម និងមូលធនម្ចាស់ភាគហ៊ុនសរុប** | | **16,526,325** | **67,328,249** | **13,805,582** | **55,843,581** |

*កំណត់សម្គាល់ពីលេខ 1 ដល់ 23 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លទ្ធផលពេញលេញ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021

| | *កំណត់សម្គាល់* | *2021* | | *2020* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **ចំណូលប្រតិបត្តិការ** | | | | | |
| ចំណូលការប្រាក់ | 16 | 2,146,443 | 8,731,730 | 2,316,529 | 9,444,489 |
| ចំណាយការប្រាក់ | 17 | (535,366) | (2,177,869) | (612,511) | (2,497,207) |
| **ចំណូលការប្រាក់សុទ្ធ** | | **1,611,077** | **6,553,861** | **1,704,018** | **6,947,282** |
| ចំណូលប្រតិបត្តិការផ្សេងៗ | 18 | 149,105 | 606,559 | 145,868 | 594,704 |
| **ចំណូលប្រតិបត្តិការសរុប** | | **1,760,182** | **7,160,420** | **1,849,886** | **7,541,986** |
| ចំណាយបុគ្គលិក | 19 | (950,576) | (3,866,943) | (821,466) | (3,349,117) |
| រំលស់ | 9,10 | (42,660) | (173,541) | (46,524) | (189,678) |
| ចំណាយប្រតិបត្តិការផ្សេងៗ | 20 | (345,114) | (1,403,924) | (379,629) | (1,547,747) |
| សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន | 7 | (80,580) | (327,799) | (59,235) | (241,501) |
| **ចំណេញមុនពេលបង់ពន្ធ** | | **341,252** | **1,388,213** | **543,032** | **2,213,943** |
| ចំណាយពន្ធលើប្រាក់ចំណូល | 11 | (76,186) | (309,925) | (117,673) | (479,753) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **265,066** | **1,078,288** | **425,359** | **1,734,190** |
| *ធាតុចំណេញពេញលេញផ្សេងៗ៖* | | - | - | | |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | | - | 284,837 | - | (140,761) |
| **ចំណេញពេញលេញសរុប** | | **265,066** | **1,363,125** | **425,359** | **1,593,429** |

*កំណត់សម្គាល់ពីលេខ 1 ដល់ 23 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021

| | *ដើមទុន* | | *ប្រាក់ចំណេញរក្សាទុក* | | *ទុនបម្រុងបទប្បញ្ញត្តិ* | | *លម្អៀងបង្គរពីការប្រែសម្រួលរូបិយប័ណ្ណ* | *សរុប* | |
|---|---|---|---|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* | *សមមូលពាន់រៀល* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| **ថ្ងៃទី1 ខែមករា ឆ្នាំ2021** | 3,593,000 | 14,372,000 | 713,131 | 2,912,314 | 357,594 | 1,452,585 | 127,871 | 4,663,725 | 18,864,770 |
| ដើមទុនបន្ថែម | 2,000,000 | 8,000,00 | - | - | - | - | - | 2,000,000 | 8,000,000 |
| ប្រាក់ចំណេញសុទ្ធ | - | | 265,066 | 1,078,288 | - | - | - | 265,066 | 1,078,288 |
| ផ្ទេរទៅទុនបម្រុងបទប្បញ្ញត្តិ | - | | (223,449) | (910,331) | 223,449 | 910,331 | - | - | - |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | - | | - | - | - | - | 284,837 | - | 284,837 |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | **5,593,000** | **22,372,000** | **754,748** | **3,080,271** | **581,043** | **2,362,916** | **412,708** | **6,928,791** | **28,227,895** |
| **ថ្ងៃទី1 ខែមករា ឆ្នាំ2020** | 3,593,000 | 14,372,000 | 575,726 | 2,352,112 | 69,640 | 278,597 | 268,632 | 4,238,366 | 17,271,341 |
| ប្រាក់ចំណេញសុទ្ធ | - | | 425,359 | 1,734,190 | - | - | - | 425,359 | 1,734,190 |
| ផ្ទេរទៅទុនបម្រុងបទប្បញ្ញត្តិ | - | | (287,954) | (1,173,988) | 287,954 | 1,173,988 | - | - | - |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | - | | - | - | - | - | (140,761) | - | (140,761) |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2020** | **3,593,000** | **14,372,000** | **713,131** | **2,912,314** | **357,594** | **1,452,585** | **127,871** | **4,663,725** | **18,864,770** |

*កំណត់សម្គាល់ពីលេខ 1 ដល់ 23 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021

| | *កំណត់សម្គាល់* | *2021* | | *2020* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនគិតពន្ធ | | 341,252 | 1,388,213 | 543,032 | 2,213,943 |
| *ការធ្វើនិយ័តកម្មទៅលើ៖* | | | | | |
| រំលស់ទ្រព្យ និងហត្ថូបករណ៍ | 9 | 35,877 | 145,948 | 34,581 | 140,987 |
| រំលស់ទ្រព្យអរូបិយ | 10 | 6,784 | 27,597 | 11,943 | 48,692 |
| សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទាន | | 80,580 | 327,799 | 59,235 | 241,501 |
| *បម្រែបម្រួលទ្រព្យសកម្ម និងទ្រព្យអកម្ម៖* | | | | | |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 7 | (2,164,799) | (8,806,402) | (337,862) | (1,377,463) |
| ទ្រព្យសកម្មផ្សេងៗ | 8 | (19,362) | (78,765) | (24,232) | (98,794) |
| ប្រាក់បញ្ញើតាមតម្រូវការ | 5 | (100,000) | (406,800) | - | - |
| ទ្រព្យអកម្មផ្សេងៗ | 13 | (26,870) | (109,307) | (87,757) | (357,785) |
| **សាច់ប្រាក់ (ប្រើក្នុង) ទទួលបានពីសកម្មភាពប្រតិបត្តការ** | | **(1,846,538)** | **(7,511,717)** | **198,940** | **811,081** |
| ពន្ធលើប្រាក់ចំណូលបានបង់ | 11.2 | (49,569) | (201,647) | (92,646) | (377,718) |
| **សាច់ប្រាក់សុទ្ធ (ប្រើក្នុង) ទទួលបានពីសកម្មភាពប្រតិបត្តិការ** | | **(1,896,107)** | **(7,713,364)** | **106,294** | **433,363** |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងហត្ថូបករណ៍ | 9 | **(47,496)** | **(193,214)** | **(71,722)** | **(292,411)** |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | 12 | 8,807,064 | 35,827,136 | 12,490,570 | 50,924,054 |
| ការទូទាត់សងប្រាក់កម្ចី | 12 | (8,345,450) | (33,949,291) | (12,409,668) | (50,594,216) |
| សាច់ប្រាក់បានពីការបន្ថែមដើមទុន | | 2,000,000 | 8,136,000 | - | - |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញវត្ថុ** | | **2,461,614** | **10,013,845** | **80,902** | **329,838** |
| **ការកើនឡើង នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | **518,011** | **2,107,267** | **115,474** | **470,790** |
| សាច់ប្រាក់និង សាច់ប្រាក់សមមូលដើមគ្រា | | 353,758 | 1,430,951 | 238,284 | 971,007 |
| លម្អៀងពីការប្រែសម្រួលអត្រាប្តូរប្រាក់ | | | 13,369 | - | (10,846) |
| **សាច់ប្រាក់និង សាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | 4 | **871,769** | **3,551,587** | **353,758** | **1,430,951** |

ពត៌មានបន្ថែមទៅលើលំហូរសាច់ប្រាក់ប្រតិបត្តិការដែលបានពីការប្រាក់៖

| | | | | |
|---|---|---|---|---|
| ការប្រាក់ទទួលបាន | 2,158,521 | 8,780,863 | 2,261,854 | 9,221,579 |
| ការបង់ការប្រាក់ | 556,007 | 2,261,836 | 593,284 | 2,418,819 |

*កំណត់សម្គាល់ពីលេខ 1 ដល់ 23 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។*

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

## 1. ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាប័ណ្ណ និងបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតតាមបញ្ជីការលេខ Co. 0700 KH/2010 ចុះថ្ងៃទី6 ខែមេសា ឆ្នាំ2010។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា ក្នុងការធ្វើប្រតិបត្តិការសេវាកម្មមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី29 ខែកក្កដា ឆ្នាំ2010។

ទស្សនៈវិស័យរបស់ក្រុមហ៊ុន គឺដើម្បីក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏មានទំនុកចិត្ត ក្នុងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន ភាពឆ្នៃប្រឌិតដល់ប្រជាជនកម្ពុជា និងរក្សាបាននូវអត្ថប្រយោជន៍ជូនអតិថិជន និយោជិក ភាគទុនិក និងសង្គមជាតិទាំងមូល។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងមានឥទ្ធិពលដល់សហគមន៍សហគ្រាសធុនតូច និងមធ្យម និងកសិករ ជាពិសេស ប្រកបដោយប្រសិទ្ធភាព និរន្តភាព និងភាពទំនួលខុសត្រូវខ្ពស់។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន ស្ថិតនៅផ្ទះលេខ101អា ផ្លូវលេខ289 សង្កាត់បឹងកក់ទី1 ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### *និយោជិក*

និយោជិកទាំងអស់របស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 មានចំនួន 126នាក់ (2020៖ 120 នាក់)។

### *សេចក្តីអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ*

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលនៅ ថ្ងៃទី22 ខែមេសា ឆ្នាំ2022។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ

### *មូលដ្ឋាននៃបទបង្ហាញ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក និងរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

ការបកប្រែប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងគោលការណ៍តម្រូវតាម CIFRS for SMEs ដោយប្រើប្រាស់អត្រាចុងគ្រា និងអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*មូលដ្ឋាននៃបទបង្ហាញ* (តពីទំព័រមុន)

ទ្រព្យសកម្ម និងទ្រព្យអកម្មត្រូវបានបកប្រែតាមអត្រាចុងគ្រានៃការិយបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ចំណែកចំណូល និងចំណាយត្រូវបានបកប្រែជាខ្មែររៀលតាមអត្រាជាមធ្យមសម្រាប់ការិយបរិច្ឆេទបញ្ចប់។ រាល់ភាពខុសគ្នា នៃលទ្ធផលនៃការប្រែសម្រួលតាមអត្រាប្តូរប្រាក់ត្រូវបានទទួលស្គាល់ថាជាសមាសធាតុដាច់ដោយឡែកនៃមូលធន។ ការប្រែសម្រួលបែបនេះមិនគួរត្រូវបានបកស្រាយថាជាតំណាងដែលចំនួនដុល្លារអាមេរិកតំណាងឲ្យ ឬ អាច ឬ អាចត្រូវបានប្តូរទៅជាប្រាក់រៀលក្នុងអត្រាមួយនោះទេ។ តម្លៃទាំងអស់គិតជាដុល្លារអាមេរិក និងខ្មែររៀលត្រូវបានបង្គត់ទៅនឹងប្រាក់ដុល្លារដែលនៅជិតបំផុតនិង មួយពាន់រៀល ("រៀល") លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញតួលេខជាប្រាក់រៀលផ្អែកលើអត្រាប្តូរប្រាក់គិតក្នុង 1 ដុល្លារអាមេរិក ដូចខាងក្រោម៖

| | *2021* | *2020* |
|---|---|---|
| អត្រាចុងគ្រា | 4,074 | 4,045 |
| អត្រាមធ្យម | 4,068 | 4,077 |

### *ឆ្នាំសារពើពន្ធ*

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុន គឺចាប់ផ្តើមពីថ្ងៃទី1 ខែមករា និងបញ្ចប់នៅថ្ងៃទី31 ខែធ្នូ។

### *រូបិយប័ណ្ណមុខងារ និងសម្រាប់ការបង្ហាញ ហើយនិងការប្តូររូបិយប័ណ្ណបរទេស*

រូបិយប័ណ្ណជាតិរបស់កម្ពុជា គឺប្រាក់រៀល។ ទោះយ៉ាងណានៅពេលក្រុមហ៊ុនធ្វើអាជីវកម្ម និងរក្សាកំណត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារ គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារជារូបិយប័ណ្ណរបស់ក្រុមហ៊ុន សម្រាប់គោលបំណងវាស់វែង និងធ្វើបទបង្ហាញព្រោះវាឆ្លុះបញ្ចាំង ពីខ្លឹមសារសេដ្ឋកិច្ចរាល់ព្រឹត្តិការណ៍ និងគ្រប់កាលៈទេសៈទាំងអស់របស់ក្រុមហ៊ុន។

ប្រតិបត្តិការ ជារូបិយប័ណ្ណផ្សេងទៀតក្រៅពីប្រាក់ដុល្លារ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់បរទេស ដែលសម្រេចនៅកាលបរិច្ឆេទប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលដែលគិតជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារដែលពុំទាន់ដោះស្រាយនៅកាលបរិច្ឆេទរបាយការណ៍ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ ដោយប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ នៅកាលបរិច្ឆេទនោះ។ ភាពខុសគ្នានៃការផ្លាស់ប្តូរដែលកើតឡើងលើការកែសម្រួលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលពេញលេញ។

### *ឧបករណ៍ហិរញ្ញវត្ថុ*

ក្រុមហ៊ុនជ្រើសរើសវិធានគណនេយ្យចែងក្នុងផ្នែកទី11 ស្តីពីឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន និងផ្នែកទី12 ស្តីពីឧបករណ៍ហិរញ្ញវត្ថុដទៃទៀត យកមកអនុវត្តទាំងស្រុង។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

***ឧបករណ៍ហិរញ្ញវត្ថុ*** (តពីទំព័រមុន)

ឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានទាំងទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យអកម្មហិរញ្ញវត្ថុ ដូចជា សាច់ប្រាក់ក្នុងដៃ គណនីចរន្តជាមួយធនាគារជាតិ នៃកម្ពុជា សមតុល្យនៅធនាគារផ្សេងៗ ឥណទាន និងបុរេប្រទានទៅអតិថិជន ទ្រព្យសកម្មផ្សេងៗ (លើកលែងតែចំណាយទូទាត់ជាមុន) ប្រាក់កម្ចី និងបំណុលផ្សេងទៀត (លើកលែងតែសំវិធានធន ប្រាក់អតីតភាពការងារ និង បំណុលពន្ធ)។

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់តែនៅពេលដែលអង្គភាពក្លាយជាភាគី នៃកិច្ចសន្យាពាក់ព័ន្ធនឹងឧបករណ៍នោះ។ ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដំបូងទៅតាមតម្លៃនាពេលប្រតិបត្តិការ លើកលែងតែកិច្ចសន្យាមានប្រតិបត្តិការហិរញ្ញប្បទាន។ ប្រតិបត្តិការហិរញ្ញប្បទាន អាចនឹងកើតឡើងប្រសិនបើការទូទាត់ត្រូវបានពន្យារពេលលើសពីរយៈពេលអាជីវកម្មធម្មតា ឬ ការទូទាត់ត្រូវបានផ្តល់ហិរញ្ញប្បទានតាមអត្រាការប្រាក់ ដែលមិនមែនជាអត្រាទីផ្សារ។ ប្រសិនបើកិច្ចសន្យានាំឲ្យមានប្រតិបត្តិការហិរញ្ញប្បទានកើតមាន ក្រុមហ៊ុនត្រូវវាស់វែងទ្រព្យសកម្ម ឬ បំណុលហិរញ្ញវត្ថុ តាមតម្លៃជាក់ស្តែង នៃការទូទាត់នាពេលអនាគតបញ្ចុះមកត្រឹមអត្រាការប្រាក់លើទីផ្សារសម្រាប់ឧបករណ៍បំណុលប្រហាក់ប្រហែល។

ថ្លៃដើមរបស់បន្ទុកប្រតិបត្តិការត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូង នៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងអស់លើកលែងតែ ឧបករណ៍ហិរញ្ញវត្ថុ ដែលបានវាស់វែងតាមតម្លៃទីផ្សារតាមរយៈប្រាក់ចំណេញ ឬ ខាត។

បន្ទាប់ពីការទទួលស្គាល់ដំបូង មូលដ្ឋានឧបករណ៍ហិរញ្ញវត្ថុទាំងអស់នឹងត្រូវបានវាស់វែងតាមថ្លៃដើមដែលបានរំលស់ ដោយប្រើវិធីសាស្ត្រគណនាការប្រាក់ប្រកបដោយប្រសិទ្ធភាព ("EIR")។

នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ក្រុមហ៊ុនត្រូវវាយតម្លៃថាតើមានភស្តុតាងជាក់ស្តែង នៃការថយចុះតម្លៃរបស់ទ្រព្យសកម្មហិរញ្ញវត្ថុណាមួយដែលត្រូវវាស់វែងដោយថ្លៃដើម ឬ ថ្លៃដើមដែលបានរំលស់។ ប្រសិនបើមានភស្តុតាងជាក់ស្តែង នៃការថយចុះតម្លៃ ក្រុមហ៊ុនត្រូវទទួលស្គាល់ការខាតបង់លើការថយចុះតម្លៃនៅក្នុងចំណេញ ឬ ខាតជាបន្ទាន់។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងដោយថ្លៃដើមដែលបានរំលស់ ការខាតបង់លើការថយចុះតម្លៃ គឺជាភាពខុសគ្នារវាងតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម និងតម្លៃជាក់ស្តែងនៃលំហូរសាច់ប្រាក់ប៉ាន់ស្មាន ដែលបានបញ្ចុះតម្លៃតាមអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព ("EIR")។ ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុ មានអត្រាការប្រាក់ប្រែប្រួល អត្រាចុះតម្លៃសម្រាប់វាស់វែងការខាតបង់បណ្តាលមកពីការថយចុះតម្លៃ គឺជាអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាពបច្ចុប្បន្នដែលបានកំណត់ក្នុងកិច្ចសន្យា។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*ឧបករណ៍ហិរញ្ញវត្ថុ* (តពីទំព័រមុន)

ក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ប្រសិនបើបរិមាណ នៃការខាតបង់ ដែលបណ្តាលមកពីការថយចុះតម្លៃ មានការថយចុះ ហើយការថយចុះនោះអាចមានការពាក់ព័ន្ធចម្បងទៅនឹងព្រឹត្តិការណ៍មួយដែលបានកើតមានបន្ទាប់ពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវធ្វើការកត់ត្រាបញ្រ្ចាសមកវិញនូវការខាតបង់ ដែលបណ្តាលមកពីការថយចុះតម្លៃ ដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬ ដោយការកែគណនីសំវិធានធន។ ការកត់ត្រាបញ្រ្ចាសនេះ មិនត្រូវធ្វើលើតម្លៃពិតគណនេយ្យ នៃទ្រព្យសកម្មហិរញ្ញវត្ថុ (បរិមាណនៃគណនីសំវិធានធនសុទ្ធ) ដែលលើសពីអ្វីដែលតម្លៃពិតគណនេយ្យមានដែលមានការថយចុះតម្លៃដែលមិនបានទទួលស្គាល់ពីមុន។ ក្រុមហ៊ុនត្រូវទទួលស្គាល់បរិមាណបញ្រ្ចាស់ទាំងអស់ក្នុង ចំណេញ ឬ ខាតបង់ភ្លាមៗ។

*ការឈប់ទទួលស្គាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ*

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

ក្រុមហ៊ុននឹងឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុតែនៅពេលៈ

- សិទ្ធិតាមកិច្ចសន្យាលើលំហូរសាច់ប្រាក់ ទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬ បានទូទាត់រួច ឬ
- ក្រុមហ៊ុនផ្ទេរទៅឲ្យភាគីផ្សេងទៀត នូវហានិភ័យ និងរង្វាន់កម្មសិទ្ធសំខាន់ៗ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- ទោះបីក្រុមហ៊ុនបានរក្សានូវហានិភ័យ និងរង្វាន់សំខាន់ៗ នៃកម្មសិទ្ធិសំខាន់ៗក៏ដោយ ក្រុមហ៊ុនបានផ្ទេរការគ្រប់គ្រងលើទ្រព្យសកម្មទាំងនោះទៅឲ្យភាគីផ្សេង ហើយភាគីផ្សេងមានលទ្ធភាពក្នុងការលក់ទ្រព្យសកម្មទាំងអស់ទៅឲ្យតតិយជនដែលមិនពាក់ព័ន្ធ ហើយ ភាគីផ្សេងនោះអាចអនុវត្តលទ្ធភាពជាឯកតោភាគី ដោយមិនចាំបាច់ដាក់លក្ខខណ្ឌបន្ថែមលើការផ្ទេរនោះទេ។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវ (ក) មិនទទួលស្គាល់ទ្រព្យសកម្ម និង (ខ) ទទួលស្គាល់ដាច់ដោយឡែកពីគ្នានូវសិទ្ធិនិងកាតព្វកិច្ច ដែលមាន ឬ ដែលបានបង្កើតឡើងនៅក្នុងការផ្ទេរ។

ប្រសិនបើការផ្ទេរមិនបានបណ្តាលឲ្យមានការមិនទទួលស្គាល់ដោយសារតែ ក្រុមហ៊ុនបានរក្សានូវហានិភ័យ និងរង្វាន់កម្មសិទ្ធិសំខាន់ៗ នៃទ្រព្យសកម្មដែលបានផ្ទេរ ហើយក្រុមហ៊ុនត្រូវបន្តទទួលស្គាល់ទ្រព្យសកម្ម ដែលបានផ្ទេរនៅក្នុងទ្រព្យសកម្មទាំងមូល ហើយត្រូវទទួលស្គាល់បំណុលហិរញ្ញវត្ថុសម្រាប់តម្លៃតបស្នងដែលទទួលបាន។ ទ្រព្យសម្បត្តិ និងបំណុលមិនត្រូវកាត់កងគ្នាឡើយ។ សម្រាប់ការិយបរិច្ឆេទបន្តបន្ទាប់ ក្រុមហ៊ុនត្រូវទទួលស្គាល់នូវ ចំណូលពីការផ្ទេរទ្រព្យសកម្ម និងចំណាយនានាដែលកើតមានលើបំណុលហិរញ្ញវត្ថុ។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

***ការមិនទទួលស្គាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ*** (តពីទំព័រមុន)

*បំណុលហិរញ្ញវត្ថុ*

បំណុលហិរញ្ញវត្ថុ មិនត្រូវបានទទួលស្គាល់នៅពេលដែលកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យាត្រូវបានបំពេញ រំសាយចោល ឬ ផុតកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយបំណុលហិរញ្ញវត្ថុផ្សេង ពីអ្នកផ្តល់ប្រាក់កម្ចីដូចគ្នាដោយមានលក្ខខណ្ឌចម្បងផ្សេងគ្នា ឬ លក្ខខណ្ឌសំខាន់ៗ នៃបំណុលដែលមានស្រាប់ត្រូវបានកែប្រែ នោះការជំនួស និងការកែប្រែទាំងនេះត្រូវបានចាត់ទុកជាការមិនទទួលស្គាល់នៃតម្លៃបំណុលហិរញ្ញវត្ថុដើម និងទទួលស្គាល់តែតម្លៃនៃបំណុលហិរញ្ញវត្ថុថ្មី ហើយភាពខុសគ្នារវាងតម្លៃពិតគណនេយ្យ នៃបំណុលហិរញ្ញវត្ថុណាមួយ នឹងត្រូវបានទទួលស្គាល់នៅក្នុង ចំណេញ ឬ ខាត។

***សាច់ប្រាក់ និងសាច់ប្រាក់សមមូល***

សម្រាប់គោលបំណង នៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់សុទ្ធ និងសមមូលសាច់ប្រាក់រួមមាន សាច់ប្រាក់នៅដៃ គណនីចរន្តជាមួយធនាគារជាតិ នៃកម្ពុជា និងធនាគារផ្សេងទៀត រួមទាំងការវិនិយោគរយៈពេលខ្លីដែលមានកាលកំណត់ដើមបីខែ ឬ ក៏តិចជាងនេះ ដែលអាចបង្វិលជាសាច់ប្រាក់ ហើយប្រឈមនឹងហានិភ័យតិចក្នុងការផ្លាស់ប្តូរតម្លៃ។

***សមតុល្យនៅធនាគារដទៃ***

សមតុល្យនៅធនាគារដទៃ ត្រូវបានកត់ត្រាតាមតម្លៃដើម។

***ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ***

ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ ត្រូវបានរក្សានៅធនាគារជាតិ នៃកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីស្ថាប័នធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ហើយត្រូវបានកំណត់ដោយភាគរយ នៃដើមទុនភាគហ៊ុនអប្បបរមា តាមការតម្រូវរបស់ធនាគារជាតិ នៃកម្ពុជា។

***ឥណទាន និងបុរេប្រទានដល់អតិថិជន***

ឥណទាន និងបុរេប្រទានដល់អតិថិជន ត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃប្រតិបត្តិការ (រាប់បញ្ចូលទាំងថ្លៃដើមប្រតិបត្តិការ) និងវាស់វែងជាបន្តបន្ទាប់ ដោយតាមថ្លៃដើមរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

នៅចុងការិយច្ឆេទរបស់របាយការណ៍នីមួយៗ តម្លៃយោងនៃឥណទាន និងបុរេប្រទានទៅអតិថិជនត្រូវបានពិនិត្យឡើងវិញ ដើម្បីកំណត់ថា តើមានភស្តុតាងជាក់ស្តែងណាមួយនៃការអន់ថយ ឬ អត់។ ប្រសិនបើមានភស្តុតាងជាក់ស្តែងនៃការចុះខ្សោយ ការខាតបង់លើអ៊ីមភែមិន ត្រូវបានទទួលស្គាល់ភ្លាមៗ ក្នុងប្រាក់ចំណេញ ឬ ការបាត់បង់។ ការខាតបង់លើឱនភាពនៃតម្លៃ គឺជាភាពខុសគ្នារវាងតម្លៃយោងឥណទាន និងបុរេប្រទាន និងតម្លៃបច្ចុប្បន្ន នៃលំហូរសាច់ប្រាក់ក្នុងអត្រាអប្បហារការប្រាក់ ដ៏មានប្រសិទ្ធភាពសម្រាប់ភាពដើមរបស់ទ្រព្យសម្បត្តិ។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*ឥណទាន និងបុរេប្រទានដល់អតិថិជន* (តពីទំព័រមុន)

ភស្តុតាងដែលបញ្ជាក់ពីភាពអន់ថយ រួមមានទិន្នន័យដែលអាចអង្កេតបាន ដែលបានមកពីការយកចិត្តទុកដាក់របស់អ្នកគ្រប់គ្រងអំពីព្រឹត្តិការណ៍បាត់បង់ដូចខាងក្រោមៈ

(ក) ការលំបាកផ្នែកហិរញ្ញវត្ថុសំខាន់ៗរបស់អ្នកខ្ចី

(ខ) ការបំពានលើកិច្ចសន្យា ដូចជាការខកខាន ឬ ការខកខានលើការប្រាក់ ឬ ការទូទាត់ប្រាក់ដើម

(គ) ភាពទៅរួចដែលអ្នកខ្ចីអាចនឹងក្ស័យធន

(ឃ) ទិន្នន័យដែលអាចអង្កេតបាន បង្ហាញថាមានការថយចុះ ដែលអាចវាស់វែងបាន នៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលបានប៉ាន់ប្រមាណពីក្រុម នៃទ្រព្យសកម្មហិរញ្ញវត្ថុ ចាប់តាំងពីការទទួលស្គាល់ដំបូង នៃទ្រព្យទាំងនោះ ទោះបីជាការថយចុះមិនទាន់ត្រូវបានកំណត់ជាមួយ នឹងទ្រព្យសកម្មនីមួយៗ នៅក្នុងក្រុម ដូចជាស្ថានភាពសេដ្ឋកិច្ចថ្នាក់ជាតិ ឬ មូលដ្ឋានមិនល្អ ឬ ការផ្លាស់ប្តូរមិនល្អនៅក្នុងលក្ខខណ្ឌវិស័យខុសៗគ្នាក៏ដោយ។

ឥណទាន និងបុរេប្រទានដល់អតិថិជនត្រូវបានដាក់ជាក្រុម ដោយផ្អែកលើលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា។

*ការកត់ត្រាបញ្ច្រាស់នៃអ៊ីមភែមិន*

ក្នុងការិយបរិច្ឆេទបន្តបន្ទាប់ ប្រសិនបើបរិមាណនៃការខាតបង់លើអ៊ីមភែមិន មានការថយចុះ ហើយការថយចុះនោះអាចមានការពាក់ព័ន្ធចម្បងទៅនឹងព្រឹត្តិការណ៍មួយ ដែលបានកើតមានបន្ទាប់ពីអ៊ីមភែមិន ត្រូវបានទទួលស្គាល់ អង្គភាពត្រូវធ្វើការកត់ត្រាបញ្ច្រាស់មកវិញនូវការខាតបង់ដែលបណ្តាលមកពីអ៊ីមភែមិន ដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬ ដោយការធ្វើនិយ័តកម្មគណនីសំវិធានធន។ ការកត់ត្រាបញ្ច្រាស់នេះ មិនត្រូវធ្វើលើតម្លៃពិតគណនេយ្យ នៃទ្រព្យសកម្មហិរញ្ញវត្ថុ (បរិមាណនៃគណនីសំវិធានធនសុទ្ធ) ដែលលើសពីអ្វីដែលតម្លៃពិតគណនេយ្យមានដែលមានការថយចុះតម្លៃដែលមិនបានទទួលស្គាល់ពីមុន។ អង្គភាពត្រូវទទួលស្គាល់បរិមាណបញ្ច្រាសទាំងអស់ក្នុង ចំណេញ ឬ ខាតបង់ភ្លាមៗ។

***ទុនបម្រុងបទប្បញ្ញត្តិ***

ទុនបម្រុងបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នារវាងសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុកដោយអនុលោមតាម CIFRS for SMEs និងបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគាជាតិ នៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរលេខ ធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីចំណាត់ថ្នាក់នៃហានិភ័យឥណទាន និងការផ្តល់សំវិធានធនសម្រាប់ស្ថាប័នធនាគារ និងហិរញ្ញវត្ថុ។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

***ទុនបម្រុងបទប្បញ្ញត្តិ*** (តពីទំព័រមុន)

ប្រកាសតម្រូវឲ្យ គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុចាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាប្រាំថ្នាក់ និងផ្តល់សំវិធានធនទូទៅ និងជាក់លាក់ដោយផ្អែកលើចំណាត់ថ្នាក់ឥណទានដូចខាងក្រោម៖

| *ចំណាត់ថ្នាក់* | *ចំនួនថ្ងៃលើសកាលកំណត់* | *អត្រាសំវិធានធន* |
|---|---|---|
| ស្តង់ដារ | 0 ថ្ងៃដល់ 14 ថ្ងៃ (រយៈពេលខ្លី) | |
| | 0 ថ្ងៃដល់ 29 ថ្ងៃ (រយៈពេលវែង) | 1% |
| ឃ្លាំមើល | 15 ថ្ងៃដល់ 30 ថ្ងៃ (រយៈពេលខ្លី) | |
| | 30 ថ្ងៃដល់ 89 ថ្ងៃ (រយៈពេលវែង) | 3% |
| ក្រោមស្តង់ដារ | 31 ថ្ងៃដល់ 60 ថ្ងៃ (រយៈពេលខ្លី) | |
| | 90 ថ្ងៃដល់ 179 ថ្ងៃ (រយៈពេលវែង) | 20% |
| សង្ស័យ | 61 ថ្ងៃដល់ 90 ថ្ងៃ (រយៈពេលខ្លី) | |
| | 180 ថ្ងៃដល់ 359 ថ្ងៃ (រយៈពេលវែង) | 50% |
| បាត់បង់ | ចាប់ពី 91 ថ្ងៃ (រយៈពេលខ្លី) | |
| | 360 ថ្ងៃ ឬ ច្រើនជាង ថ្ងៃ ឬ (រយៈពេលវែង) | 100% |

ស្ថាប័នត្រូវប្រៀបធៀបសំវិធានធនតាមបទប្បញ្ញត្តិ ជាមួយនឹង សំវិធានធនដែលបានគណនាស្របតាម CIFRS for SMEs ហើយកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ទាបជាង សំវិធានធនដែលបានគណនាស្របតាម CIFRS for SMEs គ្រឹះស្ថានធនាគារកត់ត្រាសំវិធានធនតាមការគណនាស្របតាម CIFRS for SMEs

(ii) ក្នុងករណី សំវិធានធនតាមបទប្បញ្ញត្តិ ខ្ពស់ជាង សំវិធានធនដែលបានគណនាតាម CIFRS for SMEs គ្រឹះស្ថានកត់ត្រាសំវិធានធនដែលបានគណនាស្របតាម CIFRS for SMEs និងផ្ទេរភាពខុសគ្នាពីគណនីប្រាក់ចំណេញដែលបានរក្សាទុក ទៅគណនីទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

នៅខែធ្នូ ឆ្នាំ2021 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរលេខ ធ7-021-2314 ដើម្បីផ្តល់ការណែនាំបន្ថែមដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងការចាត់ថ្នាក់ឥណទានរៀបចំឡើងវិញ ដែលបានធ្វើឡើងរហូតដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងការធ្វើសំវិធានធនតាមបទ្បបញ្ញត្តិ។ សារាចរនេះ តម្រូវឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុធ្វើការចាត់ថ្នាក់ឥណទានរៀបចំឡើងវិញ ដូចខាងក្រោម៖

- ឃ្លាំមើល ប្រសិនបើឥណទានរៀបចំឡើងវិញ មានស្ថានភាពល្អ ឬ ជាឥណទានដំណើរការ
- ក្រោមស្តង់ដារ ប្រសិនបើឥណទានរៀបចំឡើងវិញលើកទីមួយ មានស្ថានភាពដែលត្រូវការរៀបចំឥណទានឡើងវិញបន្ថែម
- សង្ស័យ ប្រសិនបើឥណទានរៀបចំឡើងវិញលើកទីពីរ មានស្ថានភាពដែលត្រូវការរៀបចំឥណទានឡើងវិញបន្ថែម
- បាត់បង់ ប្រសិនបើឥណទានរៀបចំឡើងវិញ មានស្ថានភាពមិនល្អ ដែលកំណត់ថាជាឥណទានមិនដំណើរការ

## 2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

***ទុនបម្រុងបទប្បញ្ញត្តិ*** (តពីទំព័រមុន)

ទោះបីការអនុវត្តនៃសារាចរខាងលើ ត្រូវបានលើកទឹកចិត្តសម្រាប់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ក៏មានការបំភ្លឺ និងការណែនាំជាបន្តបន្ទាប់ចេញដោយធនាគារជាតិ នៃកម្ពុជា អនុញ្ញាតឲ្យលើកពេលការអនុវត្តទៅ ឆ្នាំ2022។ ក្រុមហ៊ុន បានជ្រើសរើសលើកពេលក្នុងការអនុវត្តសារាចរទៅឆ្នាំ 2022។

***កម្ចី***

ប្រាក់កម្ចី ត្រូវបានទទួលស្គាល់ដំបូងតាមតំលៃទីផ្សារ ដោយដកចំណាយប្រតិបត្តិការផ្សេងៗ ដែលបានកើតឡើង។ បន្ទាប់ពីបានទទួលស្គាល់នូវតំលៃទីផ្សារ ប្រាក់កម្ចីដែលមានការប្រាក់ត្រូវបានវាស់វែង ដោយវាស់វែងតាមវិធីរំលស់ប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព ភាពលំអៀងណាមួយរវាងសាច់ប្រាក់កម្ចីដែលបានទទួល (ដកចំណាយប្រតិបត្តិការផ្សេងៗ) និងតម្លៃរំដោះ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលពេញលេញ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាពលើរយៈពេលនៃប្រាក់កម្ចីនោះ។

***ទ្រព្យ និងហាត្ថូបករណ៍***

ទ្រព្យ និងហាត្ថូបករណ៍ត្រូវបានថែងតាមតម្លៃដើមដោយមិនរាប់បញ្ចូលសេវាកម្មប្រចាំថ្ងៃ ដកនឹងការរំលស់បង្គរ និងសំវិធានធនលើឱនភាពនៃតម្លៃ (បើមាន)។ ការផ្លាស់ប្តូរនៅក្នុងអាយុកាលប្រើប្រាស់ត្រូវបានរាប់បញ្ចូលដោយការផ្លាស់ប្តូររយៈពេលរំលស់ ឬ វិធីសាស្ត្រដែលសមស្រប និងចាត់ទុកជាការផ្លាស់ប្តូរតាមការប៉ាន់ប្រមាណរបស់គណនេយ្យ។

ទ្រព្យ និងហាត្ថូបករណ៍ ត្រូវបានកត់តាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើអ៊ីមភែមិនប្រសិនបើមាន។ ថ្លៃដើមនៃទ្រព្យ និងហាត្ថូបករណ៍រួមមានថ្លៃទិញ និងថ្លៃដើមដែលអាចបញ្ជាក់ដោយផ្ទាល់ក្នុងការនាំយកទ្រព្យនោះទៅក្នុងស្ថានភាពការងារ និងទីតាំងរបស់វាសម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក។ នៅពេលដែលធាតុនៃទ្រព្យ និងហាត្ថូបករណ៍មានសមាសធាតុសំខាន់ៗ មានអាយុកាលប្រើប្រាស់ខុសៗគ្នា សមាសធាតុទាំងនោះត្រូវបានចាត់ទុកថាជារបស់ដាច់ដោយឡែកពីគ្នានៃទ្រព្យសម្បត្តិ និងបរិក្ខារ។

ការចំណាយជាបន្តបន្ទាប់ទាក់ទងនឹងធាតុនៃទ្រព្យ និងហាត្ថូបករណ៍ដែលត្រូវបានគេទទួលស្គាល់រួចហើយត្រូវបានបូកបន្ថែមទៅនឹងចំនួនទឹកប្រាក់យោងនៃទ្រព្យសកម្ម នៅពេលដែលភាព ដែលអាចមានផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត លើសពីបទដ្ឋាននៃការវាយតម្លៃពីដំបូងនៃការអនុវត្តទ្រព្យសម្បត្តិដែលមានស្រាប់នឹងហូរចូលទៅក្រុមហ៊ុន។ រាល់ការចំណាយជាបន្តបន្ទាប់ផ្សេងៗ ទៀតត្រូវបានទទួលស្គាល់ថាជាការចំណាយក្នុងរយៈពេលដែលវាត្រូវបានចំណាយ។

ចំណេញ ឬ ខាតដែលកើតឡើងពីការចូលនិវត្តន៍ ឬ ការជំរះធាតុនៃទ្រព្យ និងហាត្ថូបករណ៍ត្រូវបានកំណត់ថាជាភាពខុសគ្នារវាងចំណូលសុទ្ធនៃការជំរះធាតុដែលបានប៉ាន់ស្មាន នឹងចំនួនទឹកប្រាក់យោងក្នុងបញ្ជី នៃទ្រព្យសកម្មហើយត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ ឬ ខាតបង់នៅកាលបរិច្ឆេទចូលនិវត្តន៍ ឬ ជម្រះបញ្ជី។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*ទ្រព្យ និងហត្ថូបករណ៍* (តពីទំព័រមុន)

ការរំលស់ ត្រូវបានគណនាតាមមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មាននៃទ្រព្យសកម្មដោយអនុវត្តអត្រារំលស់ដូចខាងក្រោម៖

| | *2021* | *2020* |
|---|---|---|
| | | រយៈពេលដែលខ្លីជាងរវាង រយៈពេលជួល និងអាយុកាលសេដ្ឋកិច្ច |
| ការកែលម្អទ្រព្យជួល | 4ឆ្នាំ | របស់ទ្រព្យ |
| គ្រឿងបរិក្ខារការិយាល័យ | 4ឆ្នាំ | 2 - 4ឆ្នាំ |
| កំព្យូទ័រ និង ឧបករណ៍ កំព្យូទ័រ | 4ឆ្នាំ | 2ឆ្នាំ |
| យានយន្ត | 4ឆ្នាំ | 2 - 4ឆ្នាំ |

ទ្រព្យ និងហត្ថូបករណ៍ដែលបានធ្វើការរំលស់ពេញលេញត្រូវបានរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់លក់ចេញ ឬ លុបចេញពីបញ្ជី។

ប្រសិនបើ មានការចង្អុលបង្ហាញថាមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ នៃអត្រារំលស់អាយុកាលប្រើប្រាស់ ឬ តម្លៃនៅសល់នៃទ្រព្យសកម្ម នោះការរំលស់នៃទ្រព្យសម្បត្តិនោះត្រូវបានកែលម្អដោយរំពឹងទុកដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកថ្មី។

### *កម្មវិធីកុំព្យូទ័រ*

កម្មវិធីកុំព្យូទ័រ ត្រូវបានបង្ហាញជាថ្លៃដើមដោយដកចេញនូវការដករំលស់បង្គរ និងសំវិធានធន លើការស្រុតចុះតម្លៃ (បើមាន)។ វាត្រូវបានរំលស់តាមវិធីសាស្ត្ររំលស់ថេរ តាមអាយុកាល 3-4ឆ្នាំ។ ប្រសិនបើ មានការចង្អុលបង្ហាញណាមួយ ដែលមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ នៃអត្រារំលស់អាយុកាលប្រើប្រាស់ ឬ តម្លៃនៅសល់នៃកម្មវិធីកុំព្យូទ័រនោះ ការធ្វើរំលស់លើកម្មវិធីកុំព្យូទ័រ នឹងត្រូវបានកែសំរួល ដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកដែលកើតមានជាថ្មី។

### *អ៊ីមភែមិនលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

នាកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ ទ្រព្យនិងហត្ថូបករណ៍ និងកម្មវិធីកុំព្យូទ័រត្រូវបានត្រួតពិនិត្យឡើងវិញ ដើម្បីកំណត់ពីសញ្ញាណណាមួយ ដែលបង្ហាញថាទ្រព្យទាំងនោះមានអ៊ីមភែមិន។ ប្រសិនបើមានសញ្ញាណណាមួយបង្ហាញពីអ៊ីមភែមិន ទឹកប្រាក់ដែលអាចស្រង់មកវិញនៃទ្រព្យសកម្មនោះ (ឬ ក្រុមនៃទ្រព្យសកម្មដែលពាក់ព័ន្ធ) ត្រូវបានប៉ាន់ស្មាន និងប្រៀបធៀបនឹងតម្លៃពិតគណនេយ្យរបស់វា។ ប្រសិនបើចំនួនទឹកប្រាក់ ដែលអាចប្រមូលបានមកវិញមានចំនួនទាបជាងនោះចំនួន ដែលនៅក្នុងបញ្ជីត្រូវបានកាត់បន្ថយទៅជាចំនួន ដែលអាចប្រមូលបានមកវិញ ហើយការខាតបង់លើអ៊ីមភែមិន ត្រូវបានទទួលស្គាល់ភ្លាមៗ នៅក្នុងប្រាក់ចំណេញ ឬ ការបាត់បង់។

*ការគណនាចំនួនទឹកប្រាក់ដែលអាចប្រមូលបាន*

ចំនួនទឹកប្រាក់ ដែលអាចប្រមូលបានមកវិញនៃក្រុមទ្រព្យសកម្មរយៈពេលវែង គឺជាតម្លៃធំជាងរវាងថ្លៃសមស្របដកតម្លៃលក់ និងតម្លៃប្រើប្រាស់របស់វា។ តម្លៃសមស្របដកថ្លៃលក់ គឺជាចំនួនទឹកប្រាក់ដែលទទួលបានពីការលក់ទ្រព្យសកម្ម ក្នុងប្រតិបត្តិការជំហោងដៃរវាងភាគី ដែលមិនពាក់ព័ន្ធដកថ្លៃលក់។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

***អ៊ីមភែមិនលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*** (តពីទំព័រមុន)

*ការគណនាចំនួនទឹកប្រាក់ដែលអាចប្រមូលបាន* (តពីទំព័រមុន)

ដើម្បីប៉ាន់ស្មានពីតម្លៃប្រើប្រាស់ លំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ត្រូវបានធ្វើអប្បហារ ដើម្បីកំណត់តម្លៃបច្ចុប្បន្នរបស់វា ដោយប្រើប្រាស់អត្រាអប្បហារ មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការវាយតម្លៃលើតម្លៃពេលវេលា នៃសាច់ប្រាក់ក្នុងទីផ្សារបច្ចុប្បន្ន ហើយនិងហានិភ័យជាក់លាក់ណាមួយរបស់ទ្រព្យសកម្មនោះ។ ចំពោះទ្រព្យសកម្ម ដែលមិនអាចបង្កើតលំហូរចូលសាច់ប្រាក់ឯករាជ្យបានច្រើន នោះទឹកប្រាក់ដែលអាចស្រង់មកវិញត្រូវបានកំណត់ចំពោះផ្នែកបង្កើតសាច់ប្រាក់ ដែលទ្រព្យសកម្មនោះស្ថិតនៅ។

*ការកត់ត្រាបញ្ច្រាស់មកវិញនៃអ៊ីមភែមិន*

ការខាតបង់ដោយសារអ៊ីមភែមិន ត្រូវបានកត់ត្រាបញ្ច្រាស់មកវិញ ប្រសិនបើមានការប្រែប្រួលណាមួយលើការប៉ាន់ស្មានទឹកប្រាក់ ដែលអាចស្រង់មកវិញនោះ ហើយនិងប្រសិនបើកាលៈទេសៈក្រោយមកទៀតមានភាពប្រសើរឡើង ព្រមទាំងមានភស្តុតាង ដែលបង្ហាញថាកាលៈទេសៈដែលមានភាពប្រសើរឡើងនោះនៅតែមានបន្តទៅទៀត។

ការខាតបង់ដោយសារការធ្លាក់ចុះតម្លៃ ត្រូវបានកត់ត្រាបញ្ច្រាស់ត្រលប់វិញតែក្នុងកម្រិតមួយដែលតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មនោះមិនលើសពីតម្លៃពិតគណនេយ្យដែលបានកំណត់ បន្ទាប់ពីដកចេញនូវរំលស់ ប្រសិនបើមិនមានការទទួលស្គាល់ លើការខាតបង់ដោយសារការធ្លាក់ចុះ តម្លៃពីមុននោះទេ។

***អត្ថប្រយោជន៍របស់និយោជិត***

*អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី*

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីត្រូវបានបង្គរនៅក្នុងរយៈពេលហិរញ្ញវត្ថុ ដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ដោយនិយោជិករបស់ក្រុមហ៊ុន។

*ប្រាក់រំលឹកអតីតភាពការងារ*

នៅថ្ងៃទី21 ខែកញ្ញា ឆ្នាំ2018 ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាសលេខ 443 ស្តីពីការអនុវត្តន៍ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ សម្រាប់និយោជិកសហគ្រាស គ្រឹះស្ថាន និងអ្នកដែលទទួលបានការធានាការផ្តល់ឲ្យដូចមានចែងក្នុងមាត្រា 89 (ថ្មី)។ យោងតាមការប្រកាសលេខ 42 ចុះថ្ងៃទី22 ខែមីនា ឆ្នាំ2019 ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង់នេះត្រូវចាប់ផ្តើមបង់ចាប់ពីខែធ្នូ ឆ្នាំ2021 ហើយដូចមានចែងខាងក្រោមៈ

- ស្មើនឹងបីថ្ងៃត្រូវបង់នៅខែមិថុនា និង
- ស្មើនឹងបីថ្ងៃត្រូវបង់នៅខែធ្នូ

ប្រាក់រំលឹកអតីតភាពការងារមានកម្រិតអតិបរមាមិនលើសពី 6ខែ នៃប្រាក់ឈ្នួលជាមធ្យម នៅឆ្នាំនីមួយៗ។ និយោជិកនឹងមិនទទួលបានការទូទាត់ឡើយ ប្រសិនបើលាលែងពីការងារមុនថ្ងៃនៃការទូទាត់។

## 2. សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ (តពីទំព័រមុន)

*ភតិសន្យា*

ការកំណត់ ថាតើកិច្ចសន្យាមួយជាភតិសន្យា គឺឈរលើមូលដ្ឋាននៃខ្លឹមសាររបស់កិច្ចសន្យា នាកាលបរិច្ឆេទចាប់ផ្តើមដំបូង ដែលថាតើការបំពេញលក្ខខណ្ឌ នៃកិច្ចសន្យានោះអាស្រ័យទៅលើការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់ណាមួយ ឬ ច្រើន ឬ ក៏កិច្ចសន្យានោះបានផ្ទេរសិទ្ធិដើម្បីប្រើប្រាស់នូវទ្រព្យសកម្មទាំងនោះ ឬ ទេ។

*ក្រុមហ៊ុនជាភតិក:*

ការទូទាត់ភតិសន្យាប្រតិបត្តិ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលស់ស្មើភាគសម្រាប់រយៈពេលនៃភតិសន្យា។

***ពន្ធលើប្រាក់ចំណូល***

ចំណាយពន្ធលើប្រាក់ចំណេញ គឺជាផលបូករវាងពន្ធក្នុងគ្រាដែលត្រូវបង់ និងពន្ធពន្យារ។ ពន្ធក្នុងគ្រាដែលត្រូវបង់ ត្រូវបានគណនាដោយផ្អែកលើប្រាក់ចំណេញជាប់ពន្ធនៅក្នុងឆ្នាំ។

ពន្ធពន្យារលើប្រាក់ចំណូល ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្រទ្រព្យអកម្ម លើភាពខុសគ្នាបណ្តោះអាសន្ននាកាលបរិច្ឆេទរបាយការណ៍ រវាងមូលដ្ឋានពន្ធ នៃទ្រព្យសកម្ម និងទ្រព្យអកម្ម ហើយនិងតម្លៃពិតគណនេយ្យសម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យអកម្ម ត្រូវបានទទួលស្គាល់លើលម្អៀងបណ្តោះអាសន្ន ដែលជាប់ពន្ធទាំងអស់ លើកលែងតែករណីដែល ពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យអកម្ម កើតចេញពីការទទួលស្គាល់ដំបូងនៃកេរ្តិ៍ឈ្មោះអាជីវកម្ម ទ្រព្យសកម្ម ឬ ទ្រព្យអកម្ម នៅក្នុងប្រតិបត្តិការដែលមិនមែនជាការបញ្ចូលអាជីកម្មរួមគ្នា ហើយនិង មិនប៉ះពាល់ទៅលើប្រាក់ចំណេញគិតតាមគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតគិតតាមច្បាប់ពន្ធ នៅពេលដែលប្រតិបត្តិការកើតឡើង។

ពន្ធពន្យា លើប្រាក់ចំណេញជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់លើលម្អៀងបណ្តោះអាសន្នទាំងអស់ដែលអាចកាត់កងបានដូចជា ឥណទានពន្ធដែលមិនទាន់បានប្រើ និងការខាតពន្ធមិនទាន់បានប្រើ ក្នុងទំហំមួយដែលវាគឺអាចកើតឡើង ដែលប្រាក់ចំណេញជាប់ពន្ធនឹងមានគ្រប់គ្រាន់ បើធៀបទៅនឹងលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ហើយឥណទានពន្ធដែលមិនទាន់បានប្រើ និងការខាតពន្ធមិនទាន់បានប្រើ អាចប្រើប្រាស់បាន លើកលែងតែករណីដែល ពន្ធពន្យាលើប្រាក់ចំណូលជាទ្រព្យសកម្ម កើតចេញពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ឬ ទ្រព្យអកម្ម នៅក្នុងប្រតិបត្តិការ ដែលមិនមែនជាការបញ្ចូលលអាជីកម្មរួមគ្នា ហើយនិងមិនប៉ះពាល់ទៅលើប្រាក់ចំណេញគិតតាមគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតគិតតាមច្បាប់ពន្ធ នៅពេលដែលប្រតិបត្តិការកើតឡើង។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*ពន្ធលើប្រាក់ចំណូល* (តពីទំព័រមុន)

តម្លៃពិតគណនេយ្យនៃពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនាចុងកាលបរិច្ឆេទរបាយការណ៍និមួយៗ ហើយត្រូវបន្ថយមកត្រឹមកម្រិតមួយដែល ប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ នឹងមានសម្រាប់ឲ្យចំនួនទាំងអស់ ឬ មួយផ្នែកនៃពន្ធពន្យារជាទ្រព្យសកម្មអាចត្រូវបានប្រើប្រាស់។ពន្ធពន្យារជាទ្រព្យសកម្មដែលមិនបានទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនាចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់ត្រឹមកម្រិតមួយ ដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត នឹងអាចអនុញ្ញាតឲ្យកាត់កងជាមួយពន្ធពន្យារលើប្រាក់ចំណូលជាទ្រព្យសកម្មដែលអាចទទួលបាន។

ពន្ធពន្យារលើប្រាក់ចំណូលត្រូវបាន គណនា តាមអត្រាពន្ធដែលត្រូវបានរំពឹងសម្រាប់អនុវត្តលើប្រាក់ចំណេញជាប់ពន្ធ (ខាតពន្ធ) នៃការិយបរិច្ឆេទដែលគេរំពឹងថា ពន្ធពន្យារលើប្រាក់ចំណូលដែលត្រូវទទួលស្គាល់ ឬ ពន្ធលើប្រាក់ចំណេញជាទ្រព្យអកម្មដែលត្រូវទូទាត់ ដោយផ្អែកលើអត្រាពន្ធដែលបានអនុម័ត ឬ នឹងត្រូវអនុម័តនាចុងការិយបរិច្ឆេទ។

ពន្ធពន្យាលើប្រាក់ចំណេញជាទ្រព្យសកម្ម និងជាទ្រព្យអកម្មអាចត្រូវបានធ្វើការកាត់កងគ្នា ប្រសិនបើមានសិទ្ធិអនុវត្តស្របច្បាប់ ដើម្បីកាត់កងពន្ធពន្យារជាទ្រព្យសកម្មក្នុងគ្រាជាមួយនឹងពន្ធពន្យាជាទ្រព្យអកម្មក្នុងគ្រា និងពន្ធពន្យារលើប្រាក់ចំណូលទាក់ទងនឹងអង្គភាពជាប់ពន្ធតែមួយ និងអាជ្ញាធរពន្ធដារតែមួយ។

*បំណុលផ្សេងៗ*

បំណុលផ្សេងៗ ត្រូវបានចែងដោយថ្លៃដើមដែលតំណាងឲ្យតម្លៃទីផ្សារ ដែលរំពឹងថានឹងត្រូវបង់នាពេលអនាគតសម្រាប់ទំនិញនិងសេវាកម្មដែលបានទទួល។

*សំវិធានធន*

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្នជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ហើយវាអាចទៅរួចដែលលំហូរចេញនៃធនធានសេដ្ឋកិច្ចដែលទទួលបានអត្ថប្រយោជន៍ នឹងត្រូវបានទាមទារដើម្បីដោះស្រាយកាតព្វកិច្ច ហើយការប៉ាន់ប្រមាណដែលអាចទុកចិត្តបានអាចនឹងត្រូវបានធ្វើឡើង។

សំវិធានធនត្រូវបានពិនិត្យឡើងវិញនៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ និងកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានបច្ចុប្បន្ន។ នៅពេលដែលផលប៉ះពាល់នៃតម្លៃសាច់ប្រាក់មានភាពជាសារវន្ត ចំនួនទឹកប្រាក់នៃសំវិធានធន គឺជាតម្លៃបច្ចុប្បន្ននៃការចំណាយដែលរំពឹងថានឹងត្រូវបានទាមទារដើម្បីដោះស្រាយកាតព្វកិច្ច។

*យថាភាព*

បំណុលយថាហេតុ មិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមទេ ប៉ុន្តែត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់នៅរបាយការណ៍ហិរញ្ញវត្ថុរួម លុះត្រាតែលទ្ធភាព នៃការហូរចេញនៃធនធានដែលរួមបញ្ចូលផលប្រយោជន៍សេដ្ឋកិច្ច គឺនៅឆ្ងាយ។ ទ្រព្យសកម្មយថាហេតុមិនត្រូវបានទទួលស្គាល់ទេ ប៉ុន្តែត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ដើម្បីបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុនៅពេលដែលលំហូរចូលនៃផលប្រយោជន៍សេដ្ឋកិច្ចអាចនឹងកើតមាន។

2. **សេចក្តីសង្ខេបសំខាន់ៗនៃគោលនយោបាយគណនេយ្យ** (តពីទំព័រមុន)

*អត្រាការប្រាក់មានប្រសិទ្ធភាព (EIR)*

អត្រាការប្រាក់មានប្រសិទ្ធភាព (EIR) គឺជាអត្រាជាក់លាក់មួយដែលធ្វើអប្បហារលើសាច់ប្រាក់ទូទាត់ ឬ សាច់ប្រាក់ទទួលប៉ាន់ស្មាន នាពេលអនាគតតាមរយៈពេល ដែលរំពឹងទុកនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ ឲ្យស្មើរទៅនឹង ទឹកប្រាក់ដុល នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ថ្លៃដើមរំលស់នៃបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ដែលមានប្រសិទ្ធភាព ក្រុមហ៊ុនប៉ាន់ប្រមាណលំហូរសាច់ប្រាក់ដែលរំពឹងទុកដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនគិតពីឥណទានបាត់បង់ដែលរំពឹងទុក។ ការគណនារាប់បញ្ចូលទាំងថ្លៃ និងចំណុចទាំងអស់ដែលបានបង់ ឬ ទទួលបានរវាងភាគីនៃកិច្ចសន្យា ដែលជាផ្នែកសំខាន់ នៃអត្រាការប្រាក់ប្រសិទ្ធភាព តម្លៃប្រតិបត្តិការ និងថ្លៃធានារ៉ាប់រង ឬ តម្លៃអប្បហារដទៃទៀត។

ថ្លៃដើមប្រតិបត្តិការ គឺជាចំណាយបន្ថែមដែលត្រូវបានបង្កឡើងដោយផ្ទាល់ ទៅនឹងការទិញយក ដកចេញ ឬ ជម្រះចោលទ្រព្យសកម្ម ឬ បំណុលហិរញ្ញវត្ថុ។ ចំណាយកើនឡើងគឺជាតម្លៃមួយដែលនឹងមិនត្រូវបានកើតឡើង ប្រសិនបើអង្គភាពមិនបានទិញយក ដកចេញ ឬ ជំរះចោលឧបករណ៍ហិរញ្ញវត្ថុ។

*ការទទួលស្គាល់ចំណូល ឬ ចំណាយ*

ចំណូលពីការប្រាក់គឺបានមកពីឥណទាន និងបុរេប្រទានទៅកាន់អតិថិជន និងសមតុល្យជាមួយធនាគារជាតិ នៃ កម្ពុជា និងធនាគារដទៃទៀត។ ចំណូលពីការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ដែលមានប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ រួមបញ្ចូលទាំងការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់ដោយចំណាយរំលស់។

ចំណាយការប្រាក់ លើប្រាក់កម្ចីក៏ត្រូវបានគណនាដោយប្រើវិធីសាស្ត្រ EIR សម្រាប់បំណុលហិរញ្ញវត្ថុទាំងអស់ដែលត្រូវបានគិតតាមតម្លៃរំលស់។ ចំណាយការប្រាក់ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលពេញលេញ រួមបញ្ចូលទាំងការប្រាក់លើទ្រព្យអកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់ដោយចំណាយរំលស់។

*ភាគីពាក់ព័ន្ធ*

សហគ្រាស និងបុគ្គលដែលគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលតាមរយៈអន្តរការីមួយ ឬច្រើនត្រូវបានគ្រប់គ្រងដោយ ឬ ស្ថិតក្រោមការគ្រប់គ្រងរួមជាមួយក្រុមហ៊ុន ដោយរួមបញ្ចូលទាំងការកាន់កាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងទៀត ដែលជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ សហការី និងបុគ្គលដែលមានកម្មសិទ្ធលើផលប្រយោជន៍ ដោយប្រយោលលើសិទ្ធិក្នុងការបោះឆ្នោតនៃគណៈអ្នកគ្រប់គ្រងដែលផ្តល់ឲ្យពួកគេនូវឥទ្ធិពលយ៉ាងសំខាន់ទៅលើក្រុមហ៊ុន បុគ្គលិកគ្រប់គ្រងសំខាន់ៗ រួមមាននាយក និងមន្ត្រីក្រុមហ៊ុននិងសមាជិកគ្រួសារជិតស្និទ្ធរបស់បុគ្គលទាំងនេះ និងក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយ បុគ្គលទាំងនេះក៏បង្កើតជាភាគីពាក់ព័ន្ធផងដែរ។ ក្នុងការពិចារណាលើទំនាក់ទំនងរបស់អង្គភាពនីមួយៗ ដែលអាចកើតមានការយកចិត្តទុកដាក់ ត្រូវបានផ្តោតទៅលើខ្លឹមសារនៃទំនាក់ទំនង ហើយមិនត្រឹមតែជាទម្រង់ស្របច្បាប់ប៉ុណ្ណោះទេ។

## 3. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ការប៉ាន់ស្មាន និងការសន្មត់

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនតម្រូវឲ្យ គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត់ ដែលប៉ះពាល់ដល់ចំនួនទឹកប្រាក់ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ដែលពាក់ព័ន្ធ។ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គណៈគ្រប់គ្រងបានធ្វើការប៉ាន់ស្មាននិងវិនិច្ឆ័យបានល្អបំផុត នូវចំនួនជាក់លាក់ដោយផ្តល់ការពិចារណាឲ្យបានម៉ត់ចត់ទៅលើភាពជាសារវន្ត។ ការវិនិច្ឆ័យ ការប៉ាន់ប្រមាណ និងការសន្មតដែលត្រូវបានប្រើនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភ្ជាប់មកជាមួយ គឺផ្អែកលើការវាយតម្លៃរបស់គណៈគ្រប់គ្រងលើអង្គហេតុដែលពាក់ព័ន្ធ និងកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលជាក់ស្តែងអាចនឹងខុសគ្នាពីការប៉ាន់ស្មានទាំងនេះ។

មូលដ្ឋាននៃការប៉ាន់ស្មាន និង ការសន្មត់ត្រូវបានពិនិត្យឡើងវិញជាប្រចាំ។ ការពិនិត្យឡើងវិញលើការប៉ាន់ប្រមាណតាមគណនេយ្យត្រូវបានទទួលស្គាល់ក្នុងកំឡុងពេលដែលការប៉ាន់ប្រមាណ ត្រូវបានកែលសម្រួលនិងក្នុងកំឡុងពេលណាមួយដែលនឹងមាននាពេលអនាគត។

*(ក) ការវិនិច្ឆ័យសំខាន់ៗ*

នៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន គណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យដូចខាងក្រោម ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ៖

*ការកំណត់មុខងាររូបិយប័ណ្ណ*

ផ្អែកលើខ្លឹមសារសេដ្ឋកិច្ចនៃកាលៈទេសៈដែលទាក់ទងនឹងក្រុមហ៊ុន មុខងាររូបិយប័ណ្ណរបស់ក្រុមហ៊ុនត្រូវបានកំណត់ជាដុល្លារអាមេរិក។ ដុល្លារអាមេរិក គឺជារូបិយប័ណ្ណនៃស្ថានភាពសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើក្នុងកិច្ចប្រតិបត្តិការ ហើយវាជារូបិយប័ណ្ណដែលជះឥទ្ធិពលជាចំបងដល់ការលក់សេវាកម្មនិងថ្លៃដើមនៃការលក់សេវាកម្ម។

*ភតិសន្យាប្រតិបត្តិការ - ក្រុមហ៊ុនជាអ្នកជួល*

ក្រុមហ៊ុនបានចុះកិច្ចសន្យាជួលអចលនៈទ្រព្យក្រោមកិច្ចសន្យាជួលប្រតិបត្តិការ ក្នុងនាមជាអ្នកជួល។ ក្រុមហ៊ុនបានកំណត់ដោយផ្អែកលើ ការវាយតម្លៃលើលក្ខខណ្ឌនានា នៃភតិសន្យាថាភតិបតី រក្សានូវរាល់ហានិភ័យ និងផលប្រយោជន៍សំខាន់ៗ នៃភាពជាម្ចាស់លើទ្រព្យសម្បត្តិទាំងនេះ។

*(ខ) ការប៉ាន់ប្រមាណនិងការសន្មតគណនេយ្យសំខាន់ៗ*

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាននិងការសន្មតទាក់ទងនឹងអនាគត។ តាមនិយមន័យ ការប៉ាន់ស្មានតាមគណនេយ្យកម្រស្មើនឹងលទ្ធផលជាក់ស្តែងណាស់។ ការប៉ាន់ប្រមាណនិងការសន្មត់ដែលមានហានិភ័យខ្ពស់ ក្នុងការបង្កឲ្យមានការកែសំរូល ជាសារវន្តទៅនឹងចំនួនទឹកប្រាក់យោងនៃទ្រព្យសម្បត្តិ និងបំណុលត្រូវបានពិភាក្សាដូចខាងក្រោម៖

## 3. **ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ ការប៉ាន់ស្មាន និងការសន្មត់** (តពីទំព័រមុន)

*(ខ) ការប៉ាន់ប្រមាណនិងការសន្មតគណនេយ្យសំខាន់ៗ* (តពីទំព័រមុន)

*ការប៉ាន់ប្រមាណសំវិធានធនសម្រាប់ការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន*

សំវិធានធនសម្រាប់អ៊ីមភែមិន ត្រូវបានរក្សារត្រឹមកម្រិតមួយដែលចាត់ទុកថាគ្រប់គ្រាន់សម្រាប់ ឥណទាន និងបុរេប្រទានទៅអតិថិជន ដែលនិងត្រូវទទួលបាន ប៉ុន្តែមិនអាចប្រមូលបាន។ កម្រិតនៃសំវិធានធន គឺផ្អែកលើស្ថានភាពនៃឥណទាន និងបុរេប្រទានទៅអតិថិជនបទពិសោធន៍ដែលធ្លាប់ប្រមូលបានពីមុន និងកត្តាផ្សេងទៀតដែលអាចប៉ះពាល់ដល់ការប្រមូល។ សំវិធានធនត្រូវបានបង្កើតឡើងដោយកត់ត្រា ទៅក្នុងរបាយការណ៍លទ្ធផល ក្នុងទម្រង់ជាសំវិធានធានសម្រាប់ការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន។

*ការប៉ាន់ប្រមាណអាយុកាលនៃការប្រើប្រាស់លើទ្រព្យ និងឧបត្ថករណ៍ និងកម្មវិធីកុំព្យូទ័រ*

ក្រុមហ៊ុនប៉ាន់ប្រមាណលើអាយុកាលប្រើប្រាស់ ឬ អាយុកាលសេដ្ឋកិច្ចនៃទ្រព្យ និងហាត្ថូបករណ៍ និងកម្មវិធីកុំព្យូទ័រ របស់ខ្លួន ផ្អែកលើអាយុកាលរបស់ទ្រព្យសកម្មត្រូវបានគេរំពឹងថាអាចប្រើបាន។ ជារៀងរាល់ឆ្នាំក្រុមហ៊ុនពិនិត្យឡើងវិញនូវអាយុកាល ឬ អាយុកាលសេដ្ឋកិច្ចនៃទ្រព្យ និងហាត្ថូបករណ៍ និងកម្មវិធីកុំព្យូទ័រ ដោយផ្អែកលើកត្តាដែលរួមមាន ការប្រើប្រាស់ទ្រព្យសម្បត្តិ ការវាយតំលៃបច្ចេកទេសផ្ទៃក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យា បរិស្ថាននិងការប្រើប្រាស់ទ្រព្យសម្បត្តិដែលបានប៉ាន់ស្មានដោយព័ត៌មានទាក់ទងនឹងប្រភេទទ្រព្យសម្បត្តិនោះ។ វាអាចទៅរួចដែលលទ្ធផលនៃប្រតិបត្តិការនាពេលអនាគត អាចរងផលប៉ះពាល់ដោយការផ្លាស់ប្តូរការប៉ាន់ស្មានទាំងនេះដែលកើតឡើងដោយការផ្លាស់ប្តូរកត្តា ដែលបានលើកឡើង។ ការកាត់បន្ថយអាយុកាលប្រើប្រាស់ ឬ អាយុកាលសេដ្ឋកិច្ចនៃទ្រព្យនិងហាត្ថូបករណ៍ និងកម្មវិធីកុំព្យូទ័រ នឹងបង្កើនការរំលស់ និងការចំណាយរំលស់ និងការថយចុះនៃទ្រព្យ និងហាត្ថូបករណ៍ និងកម្មវិធីកុំព្យូទ័រ។

*ពន្ធ*

ភាពមិនច្បាស់លាស់អាចកើតមាន ទាក់ទងទៅនឹងការបកស្រាយបទប្បញ្ញត្តិពន្ធ ការផ្លាស់ប្តូរច្បាប់ពន្ធ ចំនួននិងពេលវេលានៃប្រាក់ចំណេញដែលជាប់ពន្ធនាពេលអនាគត។ ប្រព័ន្ធពន្ធដារនៅកម្ពុជាត្រូវបានកំណត់លក្ខណៈដោយពន្ធជាច្រើន និងច្បាប់ផ្លាស់ប្តូរជាញឹកញាប់ដែលភាគច្រើននៅមានភាពមិនច្បាស់លាស់ ចម្រូងចម្រាស់ និងអាស្រ័យលើការបកស្រាយ។ ភាពខុសគ្នាដែលកើតឡើងរវាងលទ្ធផលជាក់ស្តែង និងការសន្មត់ដែលបានធ្វើឡើង ឬ ការផ្លាស់ប្តូរនាពេលអនាគតចំពោះការសន្មត់បែបនេះអាចចាំបាច់ត្រូវការការកែតម្រូវនាពេលអនាគតចំពោះចំណូល និងចំណាយពន្ធដែលបានកត់ត្រារួចហើយ។ ក្រុមហ៊ុនបង្កើតសំវិធានធនផ្អែកលើការប៉ាន់ស្មានសមហេតុផលចំពោះផលវិបាកដែលអាចកើតមាននៃការធ្វើសវនកម្មដោយអាជ្ញាធរពន្ធដារ។

## 4. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ក្នុងដៃរួមមាន៖

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ប្រាក់ដុល្លារអាមេរិក | 171,846 | 700,101 | 182,697 | 739,009 |
| ប្រាក់រៀល | 20,629 | 84,042 | 87,576 | 354,245 |
| | **192,475** | **784,143** | **270,273** | **1,093,254** |

សម្រាប់គោលបំណង នៃការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| សាច់ប្រាក់ក្នុងដៃ | 192,475 | 784,143 | 270,273 | 1,093,254 |
| គណនីចរន្តនៅធនាគារជាតិនៃកម្ពុជា | 48,744 | 198,583 | 2,648 | 10,711 |
| សមតុល្យនៅធនាគារផ្សេង | 630,550 | 2,568,861 | 80,837 | 326,986 |
| | **871,769** | **3,551,587** | **353,758** | **1,430,951** |

## 5. សមតុល្យនៅធនាគារជាតិ នៃកម្ពុជា

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| គណនីចរន្ត | 48,744 | 198,583 | 2,648 | 10,711 |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | 279,650 | 1,139,294 | 179,650 | 726,684 |
| | **328,394** | **1,337,877** | **182,298** | **737,395** |

យោងតាងប្រកាសលេខ ខ7-00-06 ចុះថ្ងៃទី11 ខែមករា ឆ្នាំ2000 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នីមួយៗ តម្រូវឲ្យរក្សាទុកប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 5% នៃដើមទុនដែលបានចុះបញ្ជីជាមួយនឹងធនាគារជាតិ នៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃ របស់ក្រុមហ៊ុនបានឡើយ ប៉ុន្តែក្រុមហ៊ុនអាចដកយកវិញបាន នៅពេលដែលក្រុមហ៊ុនសំរេចចិត្តឈប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រាក់តម្កល់កាតព្វកិច្ច ទទួលបានអត្រាការប្រាក់ស្មើរនឹង 1/2 នៃអត្រាហិរញ្ញប្បទានរយៈពេល 6ខែ កំនត់ដោយធនាគារជាតិ នៃកម្ពុជាសម្រាប់ប្រាក់ដម្កល់កាតព្វកិច្ចជាប្រាក់រៀលខ្មែរ រីឯប្រាក់តម្កល់កាតព្វកិច្ចជាប្រាក់ដុល្លារអាមេរិក ទទួលបានអត្រាការប្រាក់ស្មើរនឹង 3/8 នៃអត្រា SIBOR រយៈពេល6ខែ។

ប្រាក់តម្កល់កាតួកិច្ចនេះ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំពី 0.04% - 0.06% (2020៖ 0.48% - 0.06%)។ ចំពោះគណនីចរន្ត ដែលបានដាក់នៅធនាគារជាតិ នៃកម្ពុជា មិនទទួលបាននូវការប្រាក់នោះទេ។

## 6. សមតុល្យនៅធនាគារផ្សេង

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ដុល្លារអាមេរិក | 584,073 | 2,379,513 | 22,808 | 92,258 |
| ខ្មែររៀល | 46,477 | 189,348 | 58,029 | 234,728 |
| | **630,550** | **2,568,861** | **80,837** | **326,986** |

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| គណនីចរន្ត | 78,085 | 318,118 | 16,898 | 68,352 |
| គណនីសន្សំ | 302,465 | 1,232,243 | 63,939 | 258,634 |
| បញ្ញើមានកាលកំណត់ ដើមច្រើនតិចជាង3ខែ | 250,000 | 1,018,500 | - | - |
| | **630,550** | **2,568,861** | **80,837** | **326,986** |

សមតុល្យនៅធនាគារផ្សេងៗ តំណាងឲ្យគណនីចរន្ត ដែលពុំទទួលបានការប្រាក់ទេ។ បញ្ញើមានកាលកំណត់ទទួលបានអត្រាការប្រាក់ 1% ក្នុងមួយឆ្នាំ។

## 7. ឥណទាន និងបុរេប្រទានទៅអតិថិជន

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ឥណទានបុគ្គល | 15,136,635 | 61,666,651 | 12,940,870 | 52,345,819 |
| ឥណទានក្រុម | 18,276 | 74,456 | 15,425 | 62,394 |
| ឥណទានបុគ្គលិក | 347,905 | 1,417,365 | 368,232 | 1,489,498 |
| **ឥណទាន និងបុរេប្រទានទៅអតិថិជន- ដុល** | **15,502,816** | **63,158,472** | **13,324,527** | **53,897,711** |
| ការប្រាក់បង្គរដែលត្រូវទទួល | 201,947 | 822,732 | 214,218 | 866,512 |
| កម្រៃពីឥណទានដែលមិនទាន់សម្រេចបាន | (136,385) | (555,632) | (135,155) | (546,702) |
| | **15,568,378** | **63,425,572** | **13,403,590** | **54,217,521** |
| សំវិធានធនសម្រាប់ការខាតបង់លើ ឥណទាននិងបុរេប្រទានទៅអតិថិជន | (365,335) | (1,488,375) | (284,766) | (1,151,878) |
| **ឥណទាន និងបុរេប្រទានទៅអតិថិជន - សុទ្ធ** | **15,203,043** | **61,937,197** | **13,118,824** | **53,065,643** |

## 7. **ឥណទាន និងបុរេប្រទានទៅអតិថិជន** (តពីទំព័រមុន)

បម្រែបម្រួលនៃសំវិធានធនសម្រាប់ការខាតបង់លើឥណទាន និងបុរេប្រទានទៅអតិថិជនមានដូចខាងក្រោម៖

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| សមតុល្យដើមគ្រា | 284,766 | 1,151,878 | 254,757 | 1,038,135 |
| សំវិធានធនក្នុងគ្រា | 80,580 | 327,799 | 59,235 | 241,501 |
| ឥណទានលុបចោល | - | - | (29,226) | (119,154) |
| ខាតពីរូបិយប័ណ្ណបរទេស | (11) | (45) | | |
| លម្អៀងពីការប្រែសម្រួលអត្រាប្តូររូបិយប័ណ្ណ | - | 8,743 | - | (8,604) |
| **សមតុល្យចុងគ្រា** | **365,335** | **1,488,375** | **284,766** | **1,151,878** |

ចំពោះការវិភាគទៅលើឥណទាន និងបុរេប្រទានទៅអតិថិជនមានដូចខាងក្រោម៖

*(ក) តាមទ្រព្យបញ្ចាំ*

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| មានទ្រព្យធានា | 15,458,071 | 62,976,181 | 13,294,784 | 53,777,401 |
| គ្មានទ្រព្យធានា | 44,745 | 182,291 | 29,743 | 120,310 |
| **សរុបឥណទាននិងបុរេប្រទាន-ដុល** | **15,502,816** | **63,158,472** | **13,324,527** | **53,897,711** |

*(ខ) តាមវិស័យឧស្សាហកម្ម*

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| អាជីវកម្មគ្រួសារ | 3,778,306 | 15,392,819 | 12,867,510 | 52,049,078 |
| ពាណិជ្ជកម្ម | 1,164,393 | 4,743,737 | 198,443 | 802,702 |
| សេវាកម្ម | 7,352,252 | 29,953,075 | 100,180 | 405,228 |
| កសិកម្ម | 604,157 | 2,461,336 | 27,410 | 110,873 |
| ការដឹកជញ្ជូន | 471,879 | 1,922,435 | 5,027 | 20,334 |
| សាងសង់ | 1,366,434 | 5,566,852 | 15,842 | 64,081 |
| ផ្សេងៗ | 765,395 | 3,118,218 | 110,115 | 445,415 |
| **ឥណទាននិងបុរេប្រទានសរុប-ដុល** | **15,502,816** | **63,158,472** | **13,324,527** | **53,897,711** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

## 7. ឥណទាន និងបុរេប្រទានទៅអតិថិជន (តពីទំព័រមុន)

*(គ) វិភាគសំណុំឥណទានតាម និវាសនភាព សម្ព័ន្ធញាតិ និងហានិភ័យ មានដូចខាងក្រោម៖*

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| **និវាសនភាព៖** | | | | |
| និវាសនជន | **15,502,816** | **63,158,472** | **13,324,527** | **53,897,711** |
| **តាមទំនាក់ទំនង៖** | | | | |
| សម្ព័ន្ធញាតិ | 76,563 | 311,917 | 61,476 | 248,670 |
| មិនមែនសម្ព័ន្ធញាតិ | 15,426,253 | 62,846,555 | 13,263,051 | 53,649,041 |
| | **15,502,816** | **63,158,472** | **13,324,527** | **53,897,711** |
| **ហានិភ័យ៖** | | | | |
| មិនធំ | **15,502,816** | **63,158,472** | **13,324,527** | **53,897,711** |

*(ឃ) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ)*

| | *2021* | *2020* |
|---|---|---|
| ឥណទានបុគ្គល | 6.50% - 18.00% | 7.00% - 28.00% |
| ឥណទានក្រុម | 18.00% | 18.00% |
| ឥណទានបុគ្គលិក | 13.20% - 15.60% | 13.00% - 16.00% |

## 8. ទ្រព្យសកម្មផ្សេង

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ប្រាក់កក់ | 37,400 | 152,368 | 37,400 | 151,283 |
| ចំណាយបង់មុន | 32,812 | 133,676 | 14,906 | 60,295 |
| ផ្សេងៗ | 25,806 | 105,134 | 24,350 | 98,498 |
| | **96,018** | **391,178** | **76,656** | **310,076** |
| រយៈពេលខ្លី | 88,618 | 361,030 | 43,456 | 175,782 |
| រយៈពេលវែង | 7,400 | 30,148 | 33,200 | 134,294 |
| | **96,018** | **391,178** | **76,656** | **310,076** |

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

## 9. ទ្រព្យ និងបរិក្ខារ

| | *ការកែលម្អលើទ្រព្យជួល* | *គ្រឿងបរិក្ខារការិយាល័យ* | *ឧបករណ៍កុំព្យូទ័រ* | *យានយន្ត* | *សរុប* |
|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 94,276 | 87,423 | 97,940 | 19,800 | 299,439 |
| ទិញបន្ថែម | 655 | 15,450 | 31,391 | - | 47,496 |
| ការលុបចេញពីបញ្ជី | - | - | (600) | - | (600) |
| ការធ្វើនិយ័តកម្ម | (461) | (843) | 210 | - | (1,094) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | **94,470** | **102,030** | **128,941** | **19,800** | **345,241** |
| **រំលស់បង្គរ** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2021 | 79,420 | 54,104 | 81,889 | 19,800 | 235,213 |
| រំលស់ក្នុងឆ្នាំ | 4,827 | 16,630 | 14,420 | - | 35,877 |
| ការលុបចេញពីបញ្ជី | - | - | (600) | - | (600) |
| ការធ្វើនិយ័តកម្ម | (461) | (843) | 210 | - | (1,094) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | **83,786** | **69,891** | **95,919** | **19,800** | **269,396** |
| **តម្លៃពិតគណនេយ្យ** | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | 10,684 | 32,139 | 33,022 | - | 75,845 |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់លេខ 2)* | **43,527** | **130,934** | **134,532** | **-** | **308,993** |

## 9. ទ្រព្យ និងបរិក្ខារ (តពីទំព័រមុន)

| | *ការកែលម្អលើទ្រព្យជួល* | *គ្រឿងបរិក្ខារការិយាល័យ* | *ឧបករណ៍កុំព្យូទ័រ* | *យានយន្ត* | *សរុប* |
|---|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **ថ្លៃដើម** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 79,588 | 49,068 | 81,598 | 19,800 | 230,054 |
| ទិញបន្ថែម | 13,761 | 40,537 | 17,424 | - | 71,722 |
| ការលុបចេញពីបញ្ជី | - | (2,182) | (1,082) | - | (3,264) |
| ការធ្វើនិយ័តកម្ម | 927 | - | - | - | 927 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020** | **94,276** | **87,423** | **97,940** | **19,800** | **299,439** |
| **ដករំលស់បង្គរ** | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2020 | 72,205 | 39,568 | 73,100 | 18,096 | 202,969 |
| រំលស់ក្នុងឆ្នាំ | 6,323 | 16,683 | 9,871 | 1,704 | 34,581 |
| ការលុបចេញពីបញ្ជី | - | (2,182) | (1,082) | - | (3,264) |
| ការធ្វើនិយ័តកម្ម | 892 | 35 | - | - | 927 |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020** | **79,420** | **54,104** | **81,889** | **19,800** | **235,213** |
| **តម្លៃពិតគណនេយ្យ** | | | | | |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020** | **14,856** | **33,319** | **16,051** | **-** | **64,226** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់លេខ 2)* | **60,093** | **134,775** | **64,926** | **-** | **259,794** |

## 10. កម្មវិធីកុំព្យូទ័រ

| | *2021* | *2020* |
|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **តម្លៃដើម** | | |
| នាថ្ងៃទី1 ខែមករា | 52,788 | 54,495 |
| ការលុបចេញពីបញ្ជី | - | (780) |
| ការធ្វើនិយ័តកម្ម | (108) | (927) |
| **នាថ្ងៃទី31 ខែធ្នូ** | **52,680** | **52,788** |
| **ដករំលស់បង្គរ** | | |
| នាថ្ងៃទី1 ខែមករា | 46,004 | 35,768 |
| រំលស់ក្នុងឆ្នាំ | 6,784 | 11,943 |
| ការលុបចេញពីបញ្ជី | - | (780) |
| ការធ្វើនិយ័តកម្ម | (108) | (927) |
| **នាថ្ងៃទី31 ខែធ្នូ** | **52,680** | **46,004** |
| **តម្លៃពិតគណនេយ្យ** | | |
| **នាថ្ងៃទី31 ខែធ្នូ** | **-** | **6,784** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់លេខ 2)* | **-** | **27,441** |

## 11. ពន្ធលើប្រាក់ចំណូល

លខិតប្រកាសពន្ធប្រចាំខែរបស់ក្រុមហ៊ុនត្រូវឆ្លងកាត់ការត្រួតពិនិត្យជាទៀងទាត់ដោយ អាជ្ញាធរពន្ធដារ ដោយសារការអនុវត្តច្បាប់ពន្ធ និងបទប្បញ្ញត្តិចំពោះប្រតិបត្តិការជាច្រើនប្រភេទងាយនឹងមានការបកស្រាយខុសគ្នា ចំនួនទឹកប្រាក់ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានផ្លាស់ប្តូរនៅពេលក្រោយតាមការកំណត់ចុងក្រោយរបស់អាជ្ញាធរពន្ធ។

ផ្នែកនៃចំណាយពន្ធលើប្រាក់ចំណូលសម្រាប់ការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | *2021* | | *2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ពន្ធក្នុងគ្រា | 30,912 | 125,750 | 51,733 | 210,916 |
| ពន្ធពន្យា | 45,274 | 184,175 | 65,940 | 268,837 |
| **ចំណាយពន្ធលើប្រាក់ចំណូល** | **76,186** | **309,925** | **117,673** | **479,753** |

### *11.1 ចំណាយពន្ធលើប្រាក់ចំណូលក្នុងគ្រា*

អនុលោមតាមបទប្បញ្ញត្តិស្តីពីពន្ធដារកម្ពុជា ពន្ធលើប្រាក់ចំណូលក្នុងគ្រាត្រូវបានគណនាខ្ពស់ជាងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំគុណនឹងអត្រាពន្ធ 20% នៅកាលបរិច្ឆេទរបាយការណ៍ និងអត្រាពន្ធ 1 %នៃចំណូល។

## 11. **ពន្ធលើប្រាក់ចំណូល** (តពីទំព័រមុន)

### *11.1 ចំណាយពន្ធលើប្រាក់ចំណូលក្នុងគ្រា* (តពីទំព័រមុន)

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណូល ដែលបានគណនាតាមអត្រាពន្ធតាមច្បាប់ទៅនឹងការចំណាយពន្ធលើប្រាក់ចំណូលបានបង្ហាញនៅក្នុងរបាយការណ៍ប្រាក់ចំណេញឬខាតមានដូចខាងក្រោម៖

| | *2021* | | *2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| **ចំណេញមុនបង់ពន្ធ** | **341,252** | **1,078,288** | **543,032** | **2,213,943** |
| ពន្ធលើប្រាក់ចំណូលក្នុងគ្រាតាមបទប្បញ្ញត្តិ | 68,250 | 277,641 | 108,606 | 442,789 |
| ចំណាយដែលមិនអាចកាត់កងបាន | 7,936 | 32,284 | 9,067 | 36,964 |
| **ចំណាយពន្ធលើប្រាក់ចំណូល** | **76,186** | **309,925** | **117,673** | **479,753** |

### *11.2 បំណុលពន្ធ*

| | *2021* | | *2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| សមតុល្យដើមគ្រា | 28,765 | 116,354 | 69,678 | 283,938 |
| ចំណាយពន្ធក្នុងឆ្នាំ | 30,912 | 125,750 | 51,733 | 210,916 |
| ការទូទាត់ពន្ធ | (49,569) | (201,647) | (92,646) | (377,718) |
| លម្អៀងពីអត្រាប្តូរប្រាក់ | - | 723 | - | (782) |
| **សមតុល្យចុងគ្រា** | **10,108** | **41,180** | **28,765** | **116,354** |

## 11. **ពន្ធលើប្រាក់ចំណូល** (តពីទំព័រមុន)

### *11.3 ពន្ធពន្យាជាទ្រព្យសកម្មសុទ្ធ*

ពន្ធពន្យាជាទ្រព្យសកម្ម និងបំណុលត្រូវបានទទួលស្គាល់ នៅក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | *2021* | | *2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| *ពន្ធពន្យារជាទ្រព្យសកម្ម (ទ្រព្យអកម្ម)៖* | | | | |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 27,277 | 111,126 | 27,501 | 111,241 |
| ទ្រព្យ និងបរិក្ខារ | 8,602 | 35,045 | 11,613 | 46,975 |
| ខាតពីការប្រែសម្រួលអត្រាប្តូរប្រាក់មិនទាន់សម្រេចបាន | 1,801 | 7,337 | 2,932 | 11,860 |
| សំវិធានធនលើប្រាក់អតីតភាពការងារ | 2,574 | 10,486 | 2,871 | 11,613 |
| សំវិធានធនលើការខាតបង់ឥណទាន និងបុរេប្រទានទៅអតិថិជន | (79,844) | (325,284) | (39,233) | (158,697) |
| **ពន្ធពន្យារជា (បំណុល) ទ្រព្យសកម្ម-សុទ្ធ** | **(39,590)** | **(161,290)** | **5,684** | **22,992** |

## 12. **ប្រាក់កម្ចី**

កម្ចីត្រូវបានវិភាគដូចខាងក្រោម៖

| | *2021* | | *2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| បុគ្គល | 7,515,540 | 30,618,310 | 6,830,557 | 27,629,603 |
| ស្ថាប័នហិរញ្ញវត្ថុ | 1,839,232 | 7,493,031 | 2,062,601 | 8,343,221 |
| | **9,354,772** | **38,111,341** | **8,893,158** | **35,972,824** |
| បង្គរការប្រាក់ដែលត្រូវសង | 122,432 | 498,788 | 143,073 | 578,730 |
| **សរុបប្រាក់កម្ចី** | **9,477,204** | **38,610,129** | **9,036,231** | **36,551,554** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

## 12. **ប្រាក់កម្ចី** (តពីទំព័រមុន)

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| រយៈពេលខ្លី | 5,234,995 | 21,327,370 | 5,464,976 | 22,105,828 |
| រយៈពេលវែង | 4,242,209 | 17,282,759 | 3,571,255 | 14,445,726 |
| | **9,477,204** | **38,610,129** | **9,036,231** | **36,551,554** |

ប្រាក់កម្ចីមានអត្រាការប្រាក់ប្រចាំឆ្នាំចាប់ពី 2% ទៅ 7.5% (2020៖ 2% - 7%)។

## 13. **បំណុលផ្សេងៗ**

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ការទូទាត់ជាមុនពីអតិថិជន | 27,841 | 113,424 | 2,350 | 9,506 |
| ថ្លៃវិជ្ជាជីវៈដែលត្រូវសង | 16,548 | 67,417 | 17,005 | 68,785 |
| ប្រាក់អតីតភាពការងារ | 12,868 | 52,424 | 14,353 | 58,058 |
| ពន្ធកាត់ទុកដែលត្រូវសង | 6,702 | 27,304 | 7,188 | 29,075 |
| បង្គរបុព្វលាភដែលត្រូវសង | 2,500 | 10,185 | 12,380 | 50,077 |
| បំណុលផ្សេងៗ | 4,173 | 17,001 | 23,585 | 95,402 |
| | **70,632** | **287,755** | **76,861** | **310,903** |

គណនីក្នុងបំណុលផ្សេងៗរំពឹងវានឹងទូទាត់ក្នុងរយៈពេល 1ឆ្នាំបន្ទាប់ពីចុងការិយបរិច្ឆេទរាយការណ៍។

## 14. **ដើមទុន**

*(i) ដើមទុន៖*

ដើមទុនភាគហ៊ុនដែលបានចុះបញ្ជី ប្រកាស និងទូទាត់ពេញលេញរបស់ក្រុមហ៊ុនមានតម្លៃស្មើនឹង1 ដុល្លារអាមេរិកក្នុងមួយហ៊ុនមានដូចខាងក្រោម៖

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| នាថ្ងៃទី1 ខែមករា | 3,593,000 | 14,372,000 | 3,593,000 | 14,372,000 |
| បំពេញបន្ថែម | 2,000,000 | 8,000,000 | - | - |
| **នាថ្ងៃទី31 ខែធ្នូ** | **5,593,000** | **22,372,000** | **3,593,000** | **14,372,000** |

## 14. មូលធនម្ចាស់ភាគហ៊ុន (តពីទំព័រមុន)

*(ii) កម្មសិទ្ធិ និងចំនួនភាគហ៊ុនត្រូវបានបង្ហាញដូចខាងក្រោម៖*

| | *2021* | | *2020* | |
|---|---|---|---|---|
| | *%នៃកម្មសិទ្ធិ* | *ចំនួនភាគហ៊ុន* | *%នៃកម្មសិទ្ធិ* | *ចំនួនភាគហ៊ុន* |
| លោកស្រី អ៊ូ សាន | 59.69% | 3,338,554 | 65.09% | 2,338,554 |
| លោកស្រី ឌិត នីតា | 40.31% | 2,254,446 | 34.91% | 1,254,446 |
| | **100.00%** | **5,593,000** | **100.00%** | **3,593,000** |

## 15. ទុនបម្រុងបទប្បញ្ញត្តិ

ការប្រៀបធៀបរវាងសំវិធានធនតាមបទប្បញ្ញត្តិ និងសំវិធានធនតាម CIFRS for SMEs មានដូចខាងក្រោម៖

| | *2021* | *2020* |
|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| សំវិធានធនតាមបទប្បញ្ញត្តិ | 946,378 | 642,360 |
| ដកៈសំវិធានធនតាម CIFRS for SMEs | (365,335) | (284,766) |
| **ទុនបម្រុងតាមបទប្បញ្ញត្តិ** | **581,043** | **357,594** |
| **សមមូលពាន់រៀល** *(កំណត់សម្គាល់លេខ 2)* | **2,362,916** | **1,452,585** |

## 16. ចំណូលពីការប្រាក់

ចំណូលពីការប្រាក់ទទួលបានពី៖

| | *2021* | | *2020* | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់លេខ 2)* |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | 2,142,553 | 8,715,906 | 2,316,024 | 9,442,430 |
| សមតុល្យនៅធនាគារជាតិ នៃកម្ពុជា | 132 | 537 | 505 | 2,059 |
| សមតុល្យនៅធនាគារផ្សេង | 3,758 | 15,287 | - | - |
| | **2,146,443** | **8,731,730** | **2,316,529** | **9,444,489** |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ** (តពីទំព័រមុន)
នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

## 17. ចំណាយការប្រាក់

ចំណាយការប្រាក់កើតឡើងពី ប្រាក់កម្ចីតាមកាលកំណត់ មានបង្ហាញដូចខាងក្រោម៖

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| រយៈពេលខ្លី | 300,566 | 1,222,702 | 410,004 | 1,671,586 |
| រយៈពេលវែង | 234,800 | 955,167 | 202,507 | 825,621 |
| | **535,366** | **2,177,869** | **612,511** | **2,497,207** |

## 18. ចំណូលប្រតិបត្តិការផ្សេងៗ

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ចំណូលពីប្រាក់ពិន័យលើឥណទាន | 152,822 | 621,680 | 125,760 | 512,724 |
| ចំណូលពីការជួល | 5,715 | 23,249 | 6,149 | 25,069 |
| (ខាត) ចំណេញ ពីការប្តូររូបិយប័ណ្ណ-សុទ្ធ | (9,432) | (38,370) | 13,959 | 56,911 |
| | **149,105** | **606,559** | **145,868** | **594,704** |

## 19. ចំណាយបុគ្គលិក

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ប្រាក់បៀវត្សរ៍ | 790,418 | 3,215,420 | 692,979 | 2,825,275 |
| ប្រាក់បុព្វលាភ | 64,103 | 260,771 | 61,263 | 249,769 |
| វិភាគទានទៅបេឡាជាតិរបបសន្តិសុខសង្គម | 16,064 | 65,348 | 15,440 | 62,949 |
| ការបណ្តុះបណ្តាល | 3,062 | 12,456 | 5,528 | 22,538 |
| ចំណាយផ្សេងៗ | 76,929 | 312,948 | 46,256 | 188,586 |
| | **950,576** | **3,866,943** | **821,466** | **3,349,117** |

## 20. ចំណាយប្រតិបត្តិការផ្សេងៗ

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ការជួល | 116,888 | 475,500 | 113,588 | 463,098 |
| កម្រៃជើងសារ និងពន្ធ | 37,986 | 154,527 | 28,674 | 116,904 |
| វិជ្ជាជីវៈ | 36,794 | 149,678 | 46,980 | 191,537 |
| ការដឹកជញ្ជូន និងធ្វើដំណើរ | 34,950 | 142,177 | 32,592 | 132,878 |
| សន្តិសុខ | 25,316 | 102,985 | 26,469 | 107,914 |
| ជួសជុល និងថែទាំ | 22,128 | 90,017 | 18,320 | 74,691 |
| ទឹកនិងភ្លើង | 21,971 | 89,378 | 23,260 | 94,831 |
| សម្ភារៈការិយាល័យ | 18,335 | 74,587 | 25,279 | 103,062 |
| ទូរគមនាគមន៍ | 14,120 | 57,440 | 13,820 | 56,344 |
| ផ្សាយពាណិជ្ជកម្ម | 9,882 | 40,200 | 8,298 | 33,831 |
| ការថតចម្លងឯកសារ | 722 | 2,937 | 3,572 | 14,563 |
| សំវិធានធនសម្រាប់ការកំណត់ពន្ធឡើងវិញ | - | - | 20,413 | 83,224 |
| ចំណាយផ្សេងៗ | 6,022 | 24,498 | 18,364 | 74,870 |
| | **345,114** | **1,403,924** | **379,629** | **1,547,747** |

ចំណាយផ្សេងៗ មានរួមបញ្ចូល ចំណាយលើអាហារ ចំណាយលើធានារ៉ាប់រង សប្បុរសធម៌ កម្រៃជើងសារ និងចំណាយលើសេវាធនាគារ។

## 21. សន្យា និងយថាភាព

### *21.1 សន្យាភតិសន្យា*

ក្រុមហ៊ុនមានការសន្យាភតិសន្យា លើការជួលអគារក្រោមការរៀបចំភតិសន្យាប្រតិបត្តិការ ដូចខាងក្រោម៖

| | 2021 | | 2020 | |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| តិចជាង 1 ឆ្នាំ | 87,317 | 355,204 | 95,713 | 390,222 |
| ច្រើនជាងពី 1 ឆ្នាំដល់ 5 ឆ្នាំ | 28,000 | 113,904 | 98,380 | 401,095 |
| | **115,317** | **469,108** | **194,093** | **791,317** |

## 21. **ភាគព្វកិច្ច និងយថាភាព** (តពីទំព័រមុន)

### *21.2 ពន្ធយថាភាព*

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន ដែលបណ្តាលឲ្យមានសភាពមិនច្បាស់លាស់ ដែលកើតមានឡើងនូវភាពខុសគ្នា ក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធត្រូវបានត្រួតពិនិត្យ និងតាមដានអង្កេតដោយអាជ្ញាធរពន្ធដារជាច្រើនដែលផ្តល់លទ្ធភាពតាមច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងបង់ការប្រាក់។ ពន្ធអាចរងនូវការត្រួតពិនិត្យ និងការស៊ើបអង្កេតឡើងវិញ ដោយអាជ្ញាពន្ធដារផ្សេងៗ ដែលអនុញ្ញាតិដោយច្បាប់ ក្នុងការផាកពិន័យ ដាក់ទោស និងពិន័យជាការប្រាក់។

គណៈគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធន មានលក្ខណៈ គ្រប់គ្រាន់ដោយយោងទៅតាមច្បាប់សារពើពន្ធ។ ម្យ៉ាងវិញទៀត អាជ្ញាធរប្រហែលជាមានការបកស្រាយខុសៗគ្នា និងផលប៉ះពាល់ចាប់តាំងពីពេលក្រុមហ៊ុនបានចុះបញ្ជី អាចមានចំនួនច្រើន។

## 22. **ប្រតិបត្តិការ និងសមតុល្យរបស់ភាគីសម្ព័ន្ធញាតិ**

ប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុនជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងការិយបរិច្ឆេទ ដែលត្រូវបានបង្កើត ឡើងនៅលក្ខខណ្ឌធម្មតា និងសមតុល្យមិនទាន់សងនៅចុងឆ្នាំ មានដូចខាងក្រោម៖

| *សម្ព័ន្ធញាតិ* | *សមតុល្យ ឬប្រតិបត្តិការ* | *2021* | | *2020* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល (កំណត់សម្គាល់ លេខ 2)* |
| ញាតិសម្ព័ន្ធជិតស្និតរបស់ភាគទុនិក | | | | | |
| | កម្ចី | 4,093,069 | 16,675,163 | 3,191,667 | 12,910,293 |
| | បង្គរការប្រាក់ត្រូវសង | 47,245 | 192,476 | 76,225 | 308,330 |
| | ចំណាយការប្រាក់ | 235,720 | 958,909 | 254,933 | 1,039,362 |
| បុគ្គលិកជាគណៈគ្រប់គ្រង (ចាប់ពីប្រធានទៅ) | ឥណទាន | 76,563 | 311,918 | 61,476 | 248,670 |
| | បង្គរការប្រាក់ដែលត្រូវទទួលបាន | 583 | 2,375 | 617 | 2,496 |
| | ចំណូលពីការប្រាក់ | 10,064 | 40,940 | 7,273 | 29,652 |
| | ប្រាក់ខែ និងអត្ថប្រយោជន៍ | 271,603 | 1,104,881 | 270,725 | 1,103,746 |

## 23. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរាយការណ៍

ដោយសារតែវីរុសរាតត្បាត Coronavirus នេះ ប្រទេសជាច្រើនបានតម្រូវឲ្យអង្គភាពនានាកំណត់ ឬ ផ្អាកប្រតិបត្តិការអាជីវកម្ម និងអនុវត្តការរឹតបន្តឹងលើការធ្វើដំណើរ និងវិធានការ លើការធ្វើចត្តាឡីស័ក្ត។ វិធានការណ៍ និងគោលនយោបាយទាំងនេះ មានការរំខានយ៉ាងខ្លាំង (ឬ រំពឹងថានឹងមានការរំខាន) ទៅលើសកម្មភាពរបស់អង្គភាពជាច្រើន។ ស្ថានភាពនៃការផ្ទុះឡើងនៃវីរុសក្ស៊ូណានេះ នៅតែបន្តវិវឌ្ឍន៍ ឆ្លងកាត់កាលបរិច្ឆេទ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021។ ប្រទេសកម្ពុជាក៏ស្ថិតក្នុងចំណោមប្រទេសដែលរងផលប៉ះពាល់ ដែលបង្ហាញពីការធ្លាក់ចុះនៃសេដ្ឋកិច្ច ដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោក។

ផ្អែកលើការវាយតម្លៃរបស់គណៈគ្រប់គ្រង ផលប៉ះពាល់នៃការផ្ទុះឡើងនៃជំងឺនេះ នៅមានភាពតិចតួច ដោយសារមានវិធានការការពារឥណទាន ក្នុងការគ្រប់គ្រងហានិភ័យនៃសំពៀតឥណទាន ហើយគណៈគ្រប់គ្រងគិតថា ការប៉ាន់ប្រមាណជាតួលេខលើផលប៉ះពាល់របស់វីរុសនេះ មកលើក្រុមហ៊ុន នៅមិនទាន់អាចអនុវត្តបាននោះទេ។ គណៈគ្រប់គ្រងនឹងបន្តរការយកចិត្តទុកដាក់ជានិច្ចលើស្ថានភាពនៃវីរុស COVID-19 នៅក្នុងប្រទេសកម្ពុជា ប្រតិបត្តិការឥណទានរបស់អតិថិជន ក៏ដូចជាសមត្ថភាពក្នុងការទូទាត់សងបំណុលរបស់អតិថិជន។

ក្រៅពីការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ពុំមានព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ដែលមានឥទ្ធិពលជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ឡើយ។